# បេឡាជាតិរបបសន្តិសុខសង្គម
# ( ប.ស.ស )

ធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ស្ថិរភាពសង្គម

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៣ និង ទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៤

## ជំហានទី១
## ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ


អាសយដ្ឋាន៖ អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ ០២៣ ៨៨២ ៦២៣/៨៨២ ៤៣៤
ទូរសារ៖ ០២៣ ៨៨២ ៦២៣
ទូរស័ព្ទទំនាក់ទំនងបន្ទាន់៖ ១២៨៦
សារអេឡិចត្រូនិច៖ info@nssf.gov.kh / benefit@nssf.gov.kh
គេហទំព័រ៖ www.nssf.gov.kh

បេឡាជាតិរបបសន្តិសុខសង្គម

( ប.ស.ស )

# របាយការណ៍

# ស្តីពី

# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៣

# និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៤

## ជំហានទី១

## ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

# មាតិកា


**ចក្ខុវិស័យ និងបេសកកម្ម** ..... i

**រចនាសម្ព័ន្ធចាត់តាំងបេឡាជាតិរបបសន្តិសុខសង្គម** ..... ii

**សេចក្តីផ្តើម** ..... ១

**១. ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត** ..... ២

**២. ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ** ..... ៣

២.១. ការងារបញ្ជិកា និងភាគទាន ..... ៣

២.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម ..... ៨

២.៣. ការងារតាវកាលិក ..... ៩

**៣. ការរៀបចំដាក់ឲ្យអនុវត្តរបបធានារ៉ាប់រងសុខភាព** ..... ១៥

**៤. ការងារគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស** ..... ១៧

៤.១. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ ..... ១៧

៤.២. ការងារផ្សព្វផ្សាយ ..... ១៨

៤.៣. កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្ស ..... ១៩

៤.៤. ការងារព័ត៌មានវិទ្យា ..... ២២

៤.៥. ការងារសនវកម្មផ្ទៃក្នុង ..... ២៤

**៥. ការងារគណៈកម្មការជំនាញ** ..... ២៤

៥.១. គណៈកម្មការ ស.ទ.ប.ក ..... ២៤

៥.២. គណៈកម្មការវេជ្ជសាស្ត្រ នៃបេឡាជាតិរបបសន្តិសុខសង្គម ..... ២៦

៥.៣. គណៈកម្មការរៀបចំយន្តការនៃការទូទាត់សេវាសុខាភិបាល ..... ២៧

៥.៤. ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ..... ២៧

**៦. បញ្ហាប្រឈម** ..... ២៨

**៧. វិធានការដោះស្រាយ** ..... ៣០

**៨. ទិសដៅអនុវត្តបន្តសម្រាប់ ឆ្នាំ២០១៤** ..... ៣០

**សេចក្តីសន្និដ្ឋាន** ..... ៣១

***អាស័យដ្ឋាន និងលេខទូរស័ព្ទការិយាល័យសាខា ប.ស.ស តាមបណ្តាខេត្ត*** ..... ៣៣

***មន្ទីរពេទ្យ និងមណ្ឌលសុខភាពដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស*** ..... ៣៥

***ឧបសម្ព័ន្ធ*** ..... ៣៩

***តារាងចំណាត់ថ្នាក់ហានិភ័យការងារ*** ..... ៥២

# ចក្ខុវិស័យ និងបេសកកម្ម

## ចក្ខុវិស័យ

ធានាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## បេសកកម្ម

ផ្តល់សេវាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀត ដូចជាជំងឺ និងមាតុភាពជាដើម។

# រចនាសម្ព័ន្ធចាត់តាំងបេឡាជាតិរបបសន្តិសុខសង្គម



# របាយការណ៍

## ស្ដីពី

## លទ្ធផលការងារសម្រេចបានឆ្នាំ២០១៣ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៤
## របស់បេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម បានចាប់ផ្ដើមដំណើរការរបស់ខ្លួនរហូតមកដល់ដំណាច់ ឆ្នាំ២០១៣ នេះមានរយៈពេលជាង ៥ ឆ្នាំមកហើយ ដោយបានអនុវត្តជោគជ័យនូវជំហានទី១ របបធានារ៉ាប់រងហានិភ័យការងារ និងបានត្រៀមរៀបចំនីតិវិធី និងបែបបទការងារសម្រាប់អនុវត្តជំហានទី២ របបធានារ៉ាប់រងសុខភាព ដើម្បីឲ្យកម្មករនិយោជិតទទួលបាននូវការថែទាំ និងព្យាបាលសុខភាព សម្រេចបាននូវលទ្ធផលយ៉ាងល្អប្រសើរ។ ឆ្លងកាត់រយៈពេលនេះ បេឡាជាតិរបបសន្តិសុខសង្គម បានមើលឃើញ ក៏ដូចជាទទួលបាននូវបទពិសោធន៍ជាច្រើនទាំងចំណុចខ្លាំង និងចំណុចខ្សោយដែលជាបញ្ហាប្រឈម ក៏ដូចជាស្ថានភាពនៃការអភិវឌ្ឍទាំងនៅក្នុងប្រទេស និងនៅក្នុងតំបន់ ដែលមានទំនាក់ទំនងយ៉ាងសំខាន់ជាមួយនឹងវិស័យសន្តិសុខសង្គម។ ជាអាទិ៍ការធ្វើសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ដើម្បីប្រែក្លាយអាស៊ានឲ្យទៅជាសហគមន៍តែមួយ វាសនាតែមួយ ដែលផ្ដោតសំខាន់ទៅលើសរសរស្ដម្ភបី គឺសហគមន៍នយោបាយ-សន្តិសុខ សហគមន៍សេដ្ឋកិច្ច និងសហគមន៍សង្គម-វប្បធម៌អាស៊ាន ដែលការគាំពារសង្គម ត្រូវបានលើកឡើងជាអាទិភាព និងបានបញ្ចូលទៅក្នុងសរសរស្ដម្ភទី៣ សហគមន៍សង្គមវប្បធម៌អាស៊ាន ក្នុងការរៀបចំប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គម និងការការពារពីផលប៉ះពាល់អវិជ្ជមាននៃការធ្វើសមាហរណកម្ម និងសកលភាវូបនីយកម្ម រួមមានតាមរយៈការលើកកំពស់ការផ្លាស់ប្ដូរបទពិសោធន៍នៅក្នុងប្រព័ន្ធសន្តិសុខសង្គម និងអភិវឌ្ឍស្តង់ដារសន្តិសុខសង្គមនៅក្នុងប្រទេសជាសមាជិកអោយបានកាន់តែល្អប្រសើរ។ បន្ថែមពីលើនេះ ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក៏បានផ្ដល់នូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ទាក់ទងនឹងវិស័យសន្តិសុខសង្គមឲ្យ *"ជំរុញការគិតគូរឲ្យបានល្អិតល្អន់អំពីប្រយោជន៍កម្មករនិយោជិតឲ្យបានប្រសើរ ដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព តាមរយៈការអនុវត្តច្បាប់ ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ជាជំហានបន្តទៀត ជាពិសេសត្រូវគិតគូរដល់អ្នកធ្វើការក្រៅផ្លូវការដែលមិនអាចទទួលបាននូវសោធននិវត្តន៍ អត្ថប្រយោជន៍ពេលឈឺថ្កាត់ និងការការពារលើហានិភ័យនៃការងារ ដូចជាគ្រោះថ្នាក់ និងខូចសុខភាពជាដើម"* ។

អនុលោមតាមទិដ្ឋភាពខាងលើ ស្ថានភាពរីកចំរើននៃសេដ្ឋកិច្ចជាតិ និងស្របតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បេឡាជាតិរបបសន្តិសុខសង្គម បានខិតខំប្រឹងប្រែងអនុវត្តនូវតួនាទីរបស់ខ្លួន

យ៉ាងសកម្ម និងបានរៀបចំពង្រីក ពង្រឹង និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ដែលមានចក្ខុវិស័យ និង បេសកកម្មដ៏ច្បាស់លាស់ក្នុងការអនុវត្តផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឲ្យទទួលបាននូវសេវាសន្តិសុខសង្គម នៅពេលដែលពួកគាត់ជួបប្រទះនូវយថាភាពផ្សេងៗ មានជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ និង មាតុភាពជាដើម។

បេឡាជាតិរបបសន្តិសុខសង្គម សង្ឃឹមជឿជាក់យ៉ាងមុតមាំថា របាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៣ នេះ នឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់វាស់វែង តាមដាន និងវាយតម្លៃលើការអនុវត្តន៍វិស័យសន្តិសុខសង្គម និងជាកញ្ចក់ឆ្លុះបញ្ចាំងឲ្យឃើញពីចំណុចវិជ្ជមាន ចំណុចអវិជ្ជមាន និងបញ្ហាប្រឈមនានា ដើម្បីធ្វើការកែតម្រូវ និងដំណោះស្រាយ ក្នុងការរៀបចំទិសដៅអនុវត្តការងារបន្តសម្រាប់ឆ្នាំ២០១៤ នេះឲ្យបានល្អប្រសើរថែមទៀត។

## ១. ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការកើនឡើងនូវទំហំការងារ ចំនួនសមាជិក ស្ថានភាពនៃការរីកចំរើនសេដ្ឋកិច្ច សង្គម និងតម្រូវការនៃការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋនិយាយជារួម និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិត ដែលបម្រើការងារនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន បេឡាជាតិរបបសន្តិសុខសង្គមបានខិតខំប្រឹងប្រែងបំពេញការងារទ្វេរឡើង ដោយបានរៀបចំពង្រីក ពង្រឹង និងអភិវឌ្ឍគោលនយោបាយធានារ៉ាប់រងហានិភ័យការងារបន្ថែមទៀត និងការរៀបចំផែនការការងាររយៈពេលវែង ដែលមានលក្ខណៈស៊ីជម្រៅ និង ការកសាងលិខិតបទដ្ឋានគតិយុត្តសម្រាប់ជាមូលដ្ឋាន ក្នុងការអនុវត្ត ដើម្បីធានាក្នុងការផ្តល់ សេវាសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព ទាន់ពេលវេលា និងឆ្លើយតបតាមតម្រូវការ។ ទន្ទឹមនឹងការអនុវត្ត របបធានារ៉ាប់រងហានិភ័យការងារ របបធានារ៉ាប់រងសុខភាពគឺជាគោលដៅទី២ ដែលកន្លងមកបេឡាជាតិរបបសន្តិសុខសង្គម បានបង្កើតក្រុមការងាររៀបចំដាក់ឲ្យដំណើរការរបបធានារ៉ាប់រងសុខភាព ហើយតាមរយៈក្រុមការងារនេះ ការត្រៀម

*រូបភាពទី១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃ ប.ស.ស លើកទី២ អាណត្តិទី៣ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣*



រៀបចំអនុវត្តការងារ សម្រេចបានលទ្ធផលជាច្រើនលើការរៀបចំបែបបទ នីតិវិធីការងារ និងការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដែលអាចដាក់ឲ្យដំណើរការរបបធានារ៉ាប់រងសុខភាពនៅឆ្នាំ២០១៤ នេះបាន។ ជាអាទិ៍តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន០៦ លើក នៅលើក ទី១៨ ទី១៩ និងទី២០ អាណត្តិទី២ និងលើកទី១ ទី២ និងទី៣ អាណត្តិទី៣ នេះ ការងារមួយចំនួនត្រូវបានអនុម័ត និងទទួលបានការឯកភាពយល់ព្រមពីក្រសួងអាណាព្យាបាលទាំងពីរផងដែរ។

- ផែនការយុទ្ធសាស្ត្រ អនុវត្តវិស័យសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ (២០១៣-២០១៥)។
- ការរៀបចំគោលការណ៍ដាក់អោយដំណើរការរបបធានារ៉ាប់រងសុខភាព Health Care Blue Print។
- អនុក្រឹត្យ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់អាណត្តិទី៣។*(ឧបសម្ព័ន្ធទី១)*
- អនុក្រឹត្យ ស្តីពីការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម។ *(ឧបសម្ព័ន្ធទី២)*
- សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត។*(ឧបសម្ព័ន្ធទី៣)*
- សេចក្តីសម្រេច ស្តីពីការកំណត់លាភការមុខងារសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត។
- ផែនការចំណូលចំណាយរបស់បេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ២០១៤។
- ការពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១២ របស់ ប.ស.ស។
- និងសេចក្តីព្រាងប្រកាសមួយចំនួនទៀត ទាក់ទងនឹងការអនុវត្តធានារ៉ាប់រងសុខភាព។

## ២. ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

### ២.១. ការងារបញ្ជិកា និងភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងបង់ភាគទានហានិភ័យការងារមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងដំណាក់កាលចាប់ដំណើរការដំបូង នៃបេឡាជាតិរបបសន្តិសុខសង្គម ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានណាដែលមានកម្មករនិយោជិតចំនួន ០៨ នាក់ឡើង។ អត្រាភាគទានផ្នែកហានិភ័យការងារជាអត្រាឯកភាព ដែលត្រូវបានកំណត់ស្មើនឹង ០,៨ ភាគរយនៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។ ភាគទានផ្នែកហានិភ័យការងារគឺជាកាតព្វកិច្ចដោយឡែករបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន កម្មករនិយោជិតមិនតម្រូវឲ្យមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះទេ។

*រូបភាពទី២. សកម្មភាពនៃការចុះបញ្ជិកា និងបង់ភាគទាននៅបេឡាជាតិរបបសន្តិសុខសង្គម*



## ២.១.១. ការងារចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

របាយការណ៍ដល់ដំណាច់ឆ្នាំ២០១៣ នេះ បេឡាជាតិរបបសន្តិសុខសង្គម បានពង្រីកវិសាលភាពរបបធានារ៉ាប់រងហានិភ័យការងារចំនួន *២៤* រាជធានី-ខេត្ត នៅទូទាំងប្រទេស និងបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានសរុបចំនួន ***៦.១០៧*** សហគ្រាស មានកម្មករនិយោជិតចំនួន ***៨៤៧.១៧៥*** នាក់ ក្នុងនោះស្រីមានប្រមាណ ៧២ ភាគរយ។

ដោយឡែកសម្រាប់ឆ្នាំ២០១៣ នេះ បេឡាជាតិរបបសន្តិសុខសង្គមបានទទួលចុះបញ្ជិកា សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតតាមបណ្តារាជធានី-ខេត្ត បានចំនួន ១.៥២៤ សហគ្រាស និងមានកម្មករនិយោជិតចំនួន ៧៩.០៤១ នាក់ ក្នុងនោះរាជធានីភ្នំពេញមានចំនួន ៨៣៨ សហគ្រាស ខេត្តកណ្តាល ៥៣ សហគ្រាស ខេត្តសៀមរាប ១២៥ សហគ្រាស ខេត្តព្រះសីហនុចំនួន ៤៤ សហគ្រាស ខេត្តកំពង់ចាម ៧៥ សហគ្រាស ខេត្តបាត់ដំបង ៥២ សហគ្រាស ខេត្តកំពង់ធំ ៤៧ សហគ្រាស ខេត្តរតនៈគិរីចំនួន ៥៨ សហគ្រាស និងខេត្តផ្សេងៗទៀតមានចំនួន ២៣២ សហគ្រាស។ *(ព័ត៌មានលំអិត សូមអានក្នុងតារាងឧបសម្ព័ន្ធទី៤ និងទី៥)*

*ក្រាហ្វិកទី១. ស្ថានភាពសហគ្រាស គ្រឹះស្ថាន ចុះបញ្ជិកាតាមរាជធានី-ខេត្ត នៅឆ្នាំ២០១៣*



### ២.១.២. ប្រភេទសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកា

រហូតមកដល់ដំណាច់ឆ្នាំ២០១៣ នេះ បេឡាជាតិរបបសន្តិសុខសង្គម បានទទួលចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន សរុបចំនួន ៦.១០៧ ក្នុងចំណោមនោះមានផ្នែកកាត់ដេរចំនួន ៩៥២ ផលិតកម្មស្បែកជើង ១០១ តម្បាញ ៧០ ភ្នាក់ងារដឹកជញ្ជូន ៤៤៦ សណ្ឋាគារ ៥៤៤ ភោជនីយដ្ឋាន ៧២៨ សាលាបឋមសិក្សា ១៥៨ អង្គការក្រៅរដ្ឋាភិបាល ៤៩៨ ការកាត់ រចនាថ្ម និងឥដ្ឋ ៣២១ និងសហគ្រាសផ្សេងៗទៀតចំនួន ២.២៨៩ ។ *(ទិន្នន័យលំអិត សូមអានក្នុងតារាងឧបសម្ព័ន្ធទី៦ )*

*ក្រាហ្វិកទី២. ប្រភេទសហគ្រាសបានចុះបញ្ជិកា ឆ្នាំ២០១៣*




### ២.១.៣. ស្ថានភាពសហគ្រាសបិទទ្វារ និងផ្អាកដំណើរការ

នៅក្នុងឆ្នាំ២០១៣ សហគ្រាស គ្រឹះស្ថាន បិទទ្វារឈប់ដំណើរការ និងផ្អាកដំណើរការ មានចំនួន ៣០៨ មានកម្មករនិយោជិតសរុបចំនួន ៣៤.៨៦៨ នាក់ ក្នុងនោះសហគ្រាសបិទទ្វារឈប់ដំណើរការជាស្ថាពរមានចំនួន ២៦១ មានកម្មករនិយោជិតចំនួន ៣៣.១៣២ នាក់ (សហគ្រាស នៅរាជធានីភ្នំពេញមានចំនួន ១៨៨ ខេត្តកណ្តាល ២០ ខេត្តកំពង់ស្ពឺ ០៥ ខេត្តបន្ទាយមានជ័យ ០២ ខេត្តសៀមរាប ១៣ ខេត្តស្វាយរៀង ០៦ ខេត្តព្រះសីហនុ ០៩ ខេត្តកំពង់ឆ្នាំង ០៣ ខេត្តកំពង់ចាម ០៣ ខេត្តបាត់ដំបង ០៦ ខេត្តប៉ៃលិន ០៣ ខេត្តកំពត ០២ និងខេត្តកែប ០១ )។ រីឯសហគ្រាស ផ្អាកដំណើរការបណ្តោះអាសន្នមានចំនួន ៤៧ មានកម្មករនិយោជិតចំនួន ១.៧៣៦ នាក់ (សហគ្រាស នៅរាជធានីភ្នំពេញមាន ២៨ ខេត្តកណ្តាល ០១ ខេត្តបន្ទាយមានជ័យ០១ ខេត្តសៀមរាប ០៤ ខេត្តព្រះសីហនុ ០១ ខេត្តក្រចេះ ០១ ខេត្តកំពង់ចាម ០៤ ខេត្តកំពង់ឆ្នាំង ០២ ខេត្តស្វាយរៀង ០១ ខេត្តកំពង់ធំ ០១ ខេត្តពោធិ៍សាត់ ០២ និងខេត្តស្ទឹងត្រែង ០១ )។

ជាការគួរឲ្យកត់សំគាល់ ក្នុងចំណោមសហគ្រាស គ្រឹះស្ថាន ដែលបានឈប់ដំណើរការទាំងអស់ខាងលើ រហូតមកដល់ពេលនេះ មានសហគ្រាស គ្រឹះស្ថាន មួយចំនួនបានបើកដំណើរការឡើងវិញហើយ ដែលក្នុងនោះមួយចំនួនបានប្តូរឈ្មោះ និងមួយចំនួនទៀតបានប្តូរម្ចាស់។

## ២.១.៤. ប្រៀបធៀបការងារចុះបញ្ជិកា និងចំនួនរាជធានី-ខេត្តគ្របដណ្ដប់តាមឆ្នាំ

*ក្រាហ្វិកទី៣. ការងារចុះបញ្ជិកា និងចំនួនរាជធានី-ខេត្តគ្របដណ្ដប់តាមឆ្នាំ*




តាមក្រាហ្វិកខាងលើបានបង្ហាញអោយឃើញថា ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ដែលបានចុះបញ្ជិកា នៅបេឡាជាតិរបបសន្តិសុខសង្គម តាមឆ្នាំនីមួយៗ មានការកើនឡើងជាលំដាប់។ ដែលចំនួនសហគ្រាស មានការកើនឡើងលើស ៣០ ភាគរយ និងចំនួនកម្មករនិយោជិតមានការកើនឡើងលើស ១០ ភាគរយ ប្រចាំឆ្នាំ។ ការកើនឡើងនេះ ដោយសារបេឡាជាតិរបបសន្តិសុខសង្គម បានពង្រីកវិសាលភាពគ្របដណ្ដប់ការអនុវត្តជាបន្តបន្ទាប់រហូតដល់ ២៤ រាជធានី.ខេត្ត នៅទូទាំងប្រទេសនាឆ្នាំ២០១៣ មកនេះ។ មួយវិញទៀតការកើនឡើងនេះ ក៏ដោយសារការរីកចំរើននៃសេដ្ឋកិច្ចជាតិ ដែលនាំឲ្យមានការកើនឡើងនូវចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ព្រមទាំងការចូលរួមអនុវត្តច្បាប់បានកាន់តែល្អប្រសើរផងដែរ។

## ២.១.៥. ការងារភាគទាន

ក្នុងចំនួនសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាទាំងអស់ ៦.១០៧ និងកម្មករនិយោជិតចំនួន ៨៤៧.១៧៥ នាក់ បេឡាជាតិរបបសន្តិសុខសង្គម បានដាក់ឲ្យជាប់ភាគទានចំនួន ៥.៣៤៥ សហគ្រាស ក្នុងនោះសហគ្រាសបានបង់ភាគទានមានចំនួន ***៤.៧៧១*** និងមានកម្មករនិយោជិតចំនួន ***៨៥២.២៤០*** នាក់ គិតជាភាគរយសហគ្រាសដែលបានបង់ភាគទានមានចំនួន ៨៩,២៦ ភាគរយ បើប្រៀបធៀបជាមួយនឹងសហគ្រាសដែលជាប់ភាគទាន និងកម្មករនិយោជិតបានបង់ភាគទានមានចំនួន ១០០,៥៩ ភាគរយ បើប្រៀបធៀបជាមួយកម្មករនិយោជិតបានចុះបញ្ជិកា។

***ជាការគួរឲ្យកត់សំគាល់ផងដែរ ក្នុងចំនួនសហគ្រាសដែលជាប់ភាគទានទាំងអស់ ឬកំពុងដំណើរការចំនួន ៥,៣៤៥ សហគ្រាសផ្នែកវាយនភណ្ឌ កាត់ដេរ និងស្បែកជើងមានចំនួន ៩៦០ មានកម្មករនិយោជិតចំនួន ៦១៧.៥៥០ នាក់ ក្នុងនោះផ្នែកកាត់ដេរចំនួន ៧៤៩ សហគ្រាស, ផលិតស្បែកជើង ៨៨, តម្បាញ ៥៣, បោះពុម្ព ៥៧, និងបោកគក់ចំនួន ១៣។*** *(ទិន្នន័យពីការបង់ភាគទានសូមអានក្នុងតារាងទី១ ខាងក្រោម)*

*តារាងទី១. ចំនួនសហគ្រាស គ្រឹះស្ថាន និងចំនួនកម្មករនិយោជិត បានបង់ភាគទានឆ្នាំ២០១៣*

| ខែ | ចំនួនសហគ្រាសជាប់ភាគទាន | ចំនួនសហគ្រាសបានបង់ភាគទាន | ចំនួនកម្មករនិយោជិតបានបង់ភាគទាន (នាក់) | ចំនួនសហគ្រាសមិនទាន់បានបង់ភាគទាន | ភាគរយសហគ្រាសបានបង់ភាគទាន |
|---|---|---|---|---|---|
| មករា | 4,192 | 4,140 | 766,142 | 52 | 98.76 |
| កុម្ភៈ | 4,303 | 4,239 | 773,141 | 64 | 98.51 |
| មីនា | 4,433 | 4,359 | 783,766 | 74 | 98.33 |
| មេសា | 4,562 | 4,477 | 795,573 | 85 | 98.14 |
| ឧសភា | 4,641 | 4,552 | 818,915 | 89 | 98.08 |
| មិថុនា | 4,738 | 4,636 | 833,714 | 102 | 97.85 |
| កក្កដា | 4,849 | 4,724 | 838,902 | 125 | 97.42 |
| សីហា | 4,894 | 4,735 | 860,934 | 159 | 96.75 |
| កញ្ញា | 5,071 | 4,842 | 865,721 | 229 | 95.48 |
| តុលា | 5,211 | 4,874 | 875,077 | 337 | 93.53 |
| វិច្ឆិកា | 5,345 | 4,771 | 852,240 | 574 | 89.26 |

## ២.១.៦. ប្រៀបធៀបការផ្តល់ភាគទានឆ្នាំ២០១២ និងឆ្នាំ២០១៣

*ក្រាហ្វិកទី៤. ចំនួនសហគ្រាស និងកម្មករនិយោជិតបានបង់ភាគទានឆ្នាំ២០១២ និងឆ្នាំ២០១៣ រហូតមកដល់ខែចុងក្រោយ*




បើធ្វើការគណនាតាមក្រាហ្វិកខាងលើ បានបង្ហាញឲ្យឃើញថា រហូតមកដល់ឆ្នាំ២០១៣ នេះ ចំនួនសហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទានមានការកើនឡើងចំនួន ៨៥០ សហគ្រាស ត្រូវជា ២១,៦៧ ភាគរយ និងកម្មករនិយោជិតកើនឡើងចំនួន ១០៦.៩៦៥ នាក់ ត្រូវជា ១៤,៣៥ ភាគរយ ចាប់ពីត្រឹមខែធ្នូ ឆ្នាំ២០១២ មក។ ការកើនឡើងទាំងនេះដោយសារតែ បេឡាជាតិរបបសន្តិសុខសង្គមបានពង្រឹង និងពង្រីកវិសាលភាពការអនុវត្តបាននៅទូទាំងប្រទេស និងការចូលរួមអនុវត្តច្បាប់បានល្អប្រសើរពីសំណាក់ម្ចាស់សហគ្រាស គ្រឹះស្ថាន។

## ២.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម

ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម មានមុខងារក្នុងការធានាឲ្យមានការអនុវត្តន៍ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទបញ្ញាផ្សេងៗជាធរមាន។ ផ្នែកនេះផ្តោតជាសំខាន់លើការងារមួយចំនួនមានជាអាទិ៍ ការចុះពន្យល់ណែនាំម្ចាស់សហគ្រាស គ្រឹះស្ថាន ស្តីពីការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ ដើម្បីឲ្យមានការចុះបញ្ជិកា និងបង់ភាគទាននៅបេឡាជាតិរបបសន្តិសុខសង្គម ការចុះអង្កេតគ្រោះថ្នាក់ការងារ ការស៊ើបអង្កេតអំពីស្ថានភាពរបស់អ្នករស់នៅក្នុងបន្ទុករបស់ជនរងគ្រោះ ការពង្រឹងការអនុវត្តច្បាប់ តាមរយៈការធ្វើអធិការកិច្ច ការដាក់កំហិត ការពិន័យ និងដាក់ពាក្យបណ្តឹងទៅតុលាការ ក្នុងករណីសហគ្រាស គ្រឹះស្ថានមិនព្រមអនុវត្តតាមច្បាប់ ។

### ២.២.១. *ការធ្វើអធិការកិច្ច និងកិច្ចការនីតិកម្ម*

នៅឆ្នាំ២០១៣ កន្លងមកនេះ ការងារអធិការកិច្ច និងកិច្ចការនីតិកម្មបានយកចិត្តទុកដាក់ជាចម្បងនៅក្នុងការពង្រឹង និងពង្រីកការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ បេឡាជាតិរបបសន្តិសុខសង្គម បានចាត់វិធានការចុះស្រាវជ្រាវរកសហគ្រាស គ្រឹះស្ថានថ្មីៗ ឲ្យបំពេញកាតព្វកិច្ចចុះបញ្ជិកា និងបង់ភាគទាន ចុះសម្របសម្រួលពន្យល់ណែនាំពីបែបបទការងារ ចុះធ្វើអធិការកិច្ច និងដាក់ឲ្យមានការអនុវត្តតាមច្បាប់ រួមមានការដាក់ពិន័យ និងបញ្ជូនសំណុំរឿងទៅតុលាការបានមួយចំនួន។

- ចុះស្រាវជ្រាវ សហគ្រាស គ្រឹះស្ថានថ្មីបាន ១.៩១០
- ចុះចែកលិខិតជូនដំណឹងអធិការកិច្ចបាន ២.៣៥៩ សហគ្រាស
- ចុះអធិការកិច្ច សហគ្រាស គ្រឹះស្ថានបាន ២.៦៩៦ លើក
- ចុះធ្វើកំណត់ហេតុអធិការកិច្ចផាកពិន័យបាន ១១៩ សហគ្រាស
- ចុះអធិការកិច្ចលាក់កម្មករបាន ១៥ សហគ្រាស
- ចុះអធិការកិច្ចបង់ភាគទានបាន ១១៧ សហគ្រាស
- ចុះសម្របសម្រួលសហគ្រាស គ្រឹះស្ថានចុះបញ្ជិកាបាន ១.១១៦
- ធ្វើការផាកពិន័យសហគ្រាស គ្រឹះស្ថាន (មិនចុះបញ្ជិកា,លាក់កម្មករ,មិនបង់ភាគទាន) ៣៤
- ចុះសម្របសម្រួលបង់ភាគទាន និងប្រព័ន្ធ IT សហគ្រាស គ្រឹះស្ថាន ១៤៥
- ចុះពិនិត្យមើលសហគ្រាសសុំពន្យាពេលបង់ភាគទាន ៨២
- ចុះចែកវិញ្ញាបនបត្រ សហគ្រាស គ្រឹះស្ថាន ២៥៧
- ចុះពិនិត្យ សហគ្រាស គ្រឹះស្ថានបិទ-បើក ២៤៣
- ចុះពន្យល់ពីអត្ថប្រយោជន៍ ប.ស.ស ៥១ លើក
- ចុះចែកលិខិតផាកពិន័យ សហគ្រាស ៣០

- ចុះទាររបាយការណ៍ហានិភ័យការងារ សហគ្រាស គ្រឹះស្ថាន ២៣៤
- បានចុះពិនិត្យស្ថានភាព សហគ្រាស គ្រឹះស្ថាន និងគូសប្លង់ ៣៨៩
- បានចូលរួមសវនការនៅសាលាដំបូងរាជធានី ២៥ លើក, សាលាដំបូងខេត្តកណ្ដាល ០៧ លើក និងសាលាដំបូងខេត្តព្រះសីហនុ ០៣ លើក។

### *២.២.២. ការងារអង្កេតគ្រោះថ្នាក់ការងារ*

តាមរយៈការជូនដំណឹងរបស់បណ្ដាសហគ្រាស គ្រឹះស្ថាន ពីករណីគ្រោះថ្នាក់កម្មករនិយោជិត បេឡាជាតិរបបសន្តិសុខសង្គម បានចាត់មន្ត្រីឲ្យចុះអង្កេតរកមូលហេតុគ្រោះថ្នាក់ការងារ ដើម្បីចេញសេចក្ដីសម្រេចផ្ដល់តាវកាលិកហានិភ័យការងារដល់ជនរងគ្រោះស្របតាមគោលការណ៍ច្បាប់។ សម្រាប់ ឆ្នាំ២០១៣ នេះ អធិការកិច្ចបេឡាជាតិរបបសន្តិសុខសង្គម បានទទួលរបាយការណ៍ហានិភ័យការងារចំនួន ១៦.៨៤៩ នាក់ បានអង្កេតហានិភ័យការងារចំនួន ១៧.២៤៣ នាក់ ក្នុងនោះមានគ្រោះថ្នាក់ការងារចំនួន ១៦.៧៧៥ នាក់ ( ស្រី ចំនួន ១២.០៣០ នាក់ ) និងមិនមែនគ្រោះថ្នាក់ការងារចំនួន ៤៦៨ នាក់ (ស្រីចំនួន ៣៣៣ នាក់)។ ចំនួនការអង្កេតហានិភ័យការងារ មានច្រើនជាងចំនួនរបាយការណ៍ហានិភ័យការងារ ដោយសារតែចំនួននេះបានបន្សល់ទុកពីខែមុន ដែលរបាយការណ៍មួយចំនួនត្រូវបានទទួលនៅចុងខែ ដូច្នេះចំនួននេះវានឹងបន្សល់មកដល់ខែបន្ទាប់។ *ចំពោះរបាយការណ៍ហានិភ័យការងារលំអិតសូមមើលនៅក្នុងការងារតាវកាលិក។*

*តារាងទី២. លទ្ធផលនៃការអង្កេតគ្រោះថ្នាក់ការងារឆ្នាំ២០១៣*

| **គ្រោះថ្នាក់ការងារ** | **ឆ្នាំ២០១៣** | |
|---|---|---|
| | **សរុប** | **ស្រី** |
| **ស្រាល** | ១៥.៤៤០ | ១១.៣០២ |
| **ធ្ងន់** | ១.២២៧ | ៦៩០ |
| **ជម្ងឺវិជ្ជាជីវៈ** | ១២ | ៨ |
| **ស្លាប់** | ៩៦ | ៣០ |
| **សរុប** | ១៦.៧៧៥ | |
| **មិនមែនគ្រោះថ្នាក់ការងារ** | សរុប | ស្រី |
| | ៤៦៨ | ៣៣៣ |

## **២.៣. ការងារតាវកាលិក**

បេឡាជាតិរបបសន្តិសុខសង្គម បាននឹងកំពុងរៀបចំអភិវឌ្ឍបែបបទការងារ និងពង្រីកយន្តការនៃការផ្ដល់តាវកាលិកឲ្យកាន់តែមានភាពងាយស្រួល ទូលំទូលាយបន្ថែមទៀត ដើម្បីឲ្យកម្មករនិយោជិតដែលទទួលរងនូវគ្រោះថ្នាក់ការងារ ទទួលបានសេវាប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ តាមរយៈនេះ បេឡាជាតិរបបសន្តិសុខសង្គម បានបង្កើត និងដាក់អោយប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងទិន្នន័យ

ការទាមទារតាវកាលិកហានិភ័យការងារ ដែលប្រព័ន្ធនេះអាចគ្រប់គ្រងបាននូវរបាយការណ៍ហានិភ័យការងារ ការអង្កេត និងការគណនាតាវកាលិក ដែលវាបានពន្លឿនក្នុងការផ្តល់តាវកាលិក និងមានភាពត្រឹមត្រូវ។ ប.ស.ស ក៏បានពង្រីកការចុះកិច្ចសន្យាជាមួយមន្ទីរពេទ្យ និងមន្ទីរសម្រាកព្យាបាលឯកជនបានចំនួន ៦៥ និងបានដាក់ភ្នាក់ងារឲ្យប្រចាំការនៅតាមមន្ទីរពេទ្យបានមួយចំនួន សម្រាប់ជួយសម្របសម្រួលដល់ជនរងគ្រោះ ដែលជាសមាជិករបស់ ប.ស.ស ឲ្យទទួលបានការសម្រាកព្យាបាល និងងាយស្រួលទទួលបានសេវានៅកន្លែងដែលជិត។ មួយវិញទៀតក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប.ស.ស បានបញ្ជូនមន្ត្រីទៅដល់កន្លែងគ្រោះថ្នាក់ផ្ទាល់ ដើម្បីជួយសម្របសម្រួល និងធ្វើអន្តរាគមន៍បានទាន់ពេលវេលាផងដែរ។

## *២.៣.១. របាយការណ៍ហានិភ័យការងារ*

នៅឆ្នាំ២០១៣ នេះ បេឡាជាតិរបបសន្តិសុខសង្គម បានទទួលរបាយការណ៍ហានិភ័យការងារពីបណ្តាសហគ្រាស គ្រឹះស្ថាន តាមបណ្តារាជធានី-ខេត្ត នៅទូទាំងប្រទេសចំនួន ១៤.៨៥៥ ករណី មានកម្មករនិយោជិតចំនួន ១៦.៨៤៩ នាក់ (ស្រីចំនួន ១២.០៣៤ នាក់) ហើយតាមរយៈលទ្ធផលនៃការអង្កេតមានគ្រោះថ្នាក់ការងារចំនួន ១៤.៥៦០ ករណី មានកម្មករនិយោជិត ***១៦.៧៧៥*** នាក់ (ស្រីចំនួន ១២.០៣០ នាក់) ក្នុងនោះគ្រោះថ្នាក់កន្លែងធ្វើការចំនួន ១២.០៦០ នាក់ គ្រោះថ្នាក់ពេលធ្វើដំណើរចំនួន ៤.៧០៣ នាក់ និងជម្ងឺវិជ្ជាជីវៈចំនួន ១២ នាក់។ ចំពោះកំរិតនៃរបួសវិញ មានរបួសស្រាលចំនួន ១៥.៤៤០ នាក់ របួសធ្ងន់ចំនួន ១.២២៧ នាក់ ស្លាប់ចំនួន ៩៦ និងមិនមែនជាគ្រោះថ្នាក់ការងារចំនួន ៤៦៨ នាក់។ ចំនួនរបាយការណ៍ហានិភ័យការងារ និងលទ្ធផលអង្កេតមិនដូចគ្នាទេ ជាក់ស្តែងក្នុងឆ្នាំ២០១៣ ចំនួនលទ្ធផលអង្កេតមានចំនួនច្រើនជាងរបាយការណ៍ហានិភ័យការងារនេះ ដោយសាររបាយការណ៍មួយចំនួនបានបន្សល់ទុកមកពីចុងឆ្នាំ២០១២។ *(ទិន្នន័យអំពីរបាយការណ៍ហានិភ័យការងារលំអិត សូមអានក្នុងតារាងឧបសម្ព័ន្ធទី៧)*

## *២.៣.២. របាយការណ៍ជនរងគ្រោះតាមខែ*

*ក្រាហ្វិកទី៥. របាយការណ៍ជនរងគ្រោះតាមខែ ឆ្នាំ២០១៣*



បេឡាជាតិរបបសន្តិសុខសង្គម បានទទួលរបាយការណ៍ហានិភ័យការងារពីសហគ្រាស គ្រឹះស្ថាន នៅក្នុងឆ្នាំ ២០១៣ ចំនួន ១៦.៨៤៩ នាក់ បើធៀបនឹងឆ្នាំ ២០១២ មានតែចំនួន ១៤.៧៦១ នាក់ ប៉ុណ្ណោះ ដូច្នេះចំនួននេះមានការកើនឡើង ២.០៨៨ នាក់ ត្រូវជា ១៤,១៤ ភាគរយ ។

តាមក្រាហ្វិកខាងលើក៏បានបង្ហាញឲ្យឃើញផងដែរថា ស្ថានភាពជនរងគ្រោះ តាមខែនីមួយៗ សម្រាប់ឆ្នាំ២០១៣ នេះ មានស្ថានភាពមិនដូចគ្នាទេ ក្នុងនោះនៅឆមាសទី១ ដើមឆ្នាំជនរងគ្រោះមានចំនួនតិចជាងនៅឆមាសទី២ ចំនួន ២.៦៥១ នាក់ ស្មើនឹង ៣៧,៣៤ ភាគរយ នេះដោយសារ បេឡាជាតិរបបសន្តិសុខសង្គម បានចុះទាររបាយការណ៍ហានិភ័យការងារ តាមបណ្តាសហគ្រាស គ្រឹះស្ថានដែលជំពាក់។

### ២.៣.៣. ប្រៀបធៀបស្ថានភាពគ្រោះថ្នាក់ការងារឆ្នាំ២០១២ និងឆ្នាំ២០១៣

*ក្រាហ្វិកទី៦. ចំនួនកម្មករនិយោជិតបានចុះបញ្ជិកា និងចំនួនគ្រោះថ្នាក់ការងារ*




តាមក្រាហ្វិកខាងលើបានបង្ហាញឲ្យឃើញថា ចំនួនកម្មករនិយោជិតគ្រោះថ្នាក់ការងារ ឆ្នាំ២០១៣ មានចំនួន ១៦.៧៧៥ នាក់ រីឯនៅឆ្នាំ២០១២ ចំនួនតែ ១៤.២៣៣ នាក់ ដូច្នេះចំនួននេះមានការកើនឡើង ២.៥៤២ នាក់ ត្រូវជា ១៧,៨៥ ភាគរយ។ ចំពោះកម្មករនិយោជិតបានចុះបញ្ជិកាវិញមានការកើនឡើងចំនួន ៧៩.០៤១ នាក់ ត្រូវជា ១០,២៩ ភាគរយ។ យើងឃើញថាការកើនឡើងនូវចំនួនគ្រោះថ្នាក់ការងារនេះ គឺស្របគ្នានឹងការកើនឡើងនៃចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលបានចុះបញ្ជិកានៅ ប.ស.ស ដែលចូលរួមដោយចំនួន ១០,២៩ ភាគរយ និងបាតុភាពនៃករណីសន្លប់ចំនួន ៤,៩ ភាគរយ ដូច្នេះបើប្រៀបធៀបជាមួយនឹងកំណើនកម្មករនិយោជិតដែលបានចុះបញ្ជិកា និងបាតុភាពនៃករណីសន្លប់ ***ចំនួនគ្រោះថ្នាក់ការងារជាក់ស្តែងនៅឆ្នាំ២០១៣ មានកំណើន ២,៦៦ ភាគរយ***។ ការកើនឡើងនូវចំនួនគ្រោះថ្នាក់ការងារនេះផងដែរ ក៏ដោយសារមានការកើនឡើងនូវករណីគ្រោះថ្នាក់ការងារនៅពេលធ្វើដំណើរ មានចំនួនច្រើនបន្ទាប់ពីគ្រោះថ្នាក់នៅកន្លែងធ្វើការ ដែលភាគច្រើនជាគ្រោះថ្នាក់ធ្ងន់ធ្ងរ និងបណ្តាលឲ្យបាត់បង់ជីវិតទៀតផង។

*ក្រាហ្វិកទី៧. ស្ថានភាពគ្រោះថ្នាក់ការងារតាមប្រភេទគ្រោះថ្នាក់ និងកំរិតរបួស*







ស្ថានភាពគ្រោះថ្នាក់ការងារនៅឆ្នាំ២០១៣ មានការកើនឡើងនូវគ្រប់ប្រភេទ និងកំរិតគ្រោះថ្នាក់ទាំងអស់ លើកលែងតែជម្ងឺវិជ្ជាជីវៈមានការថយចុះចំនួន ០៦ នាក់។ ប្រភេទគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការកើនឡើង ១.៤៨៧ នាក់ ត្រូវជា ១៤ ភាគរយ និងគ្រោះថ្នាក់ពេលធ្វើដំណើរកើនឡើង ១.០៦១ នាក់ ត្រូវជា ២៩ ភាគរយ។ ប្រភេទរបួសស្រាលកើនឡើង ១.៨៥៥ នាក់ ត្រូវជា ១៣,៦ ភាគរយ របួសធ្ងន់កើនឡើង ៦៥៦ នាក់ ត្រូវជា ១១៤,៨៨ ភាគរយ និងស្លាប់កើនឡើង ៣៧ នាក់ ត្រូវជា ៦២, ៧ ភាគរយ។ តាមតួលេខនេះបង្ហាញឲ្យឃើញថា ចំនួនគ្រោះថ្នាក់ការងារនៅពេលធ្វើដំណើរមានការកើនឡើងខ្ពស់ ដែលភាគច្រើនបណ្តាលឲ្យមានរបួសធ្ងន់ធ្ងរមានរហូតដល់លើស ១០០ ភាគរយ និងបណ្តាលឲ្យស្លាប់មានចំនួនរហូតដល់ជាង ៥០ ភាគរយ។ ស្ថានភាពនេះក៏បានឆ្លុះបញ្ចាំងផងដែរ ពីបញ្ហាគ្រោះថ្នាក់ចរាចរ នៅតែស្ថិតនៅក្នុងសភាពគួរឲ្យព្រួយបារម្ភសម្រាប់ប្រជាពលរដ្ឋកម្ពុជានិយាយជារួម និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិត ដែលវាជាករណីមួយមិនទាក់ទងទៅនឹងលក្ខខណ្ឌការងារនៅកន្លែងធ្វើការនោះទេ គឺវាទាក់ទងជាចម្បងជាមួយនឹងការយល់ដឹង និងការប្រុងប្រយ័ត្នរបស់កម្មករនិយោជិតខ្លួនឯងផ្ទាល់ ក្នុងការធ្វើដំណើរទៅមក ដើម្បីបំពេញការងារ។

## *២.៣.៤. ការទទួលការទាមទារតាវកាលិកហានិភ័យការងារ*

ក្នុងឆ្នាំ២០១៣ បេឡាជាតិរបបសន្តិសុខសង្គម បានទទួលការទាមទារតាវកាលិកហានិភ័យការងារសរុបចំនួន ១៥.០៥៩ នាក់ ក្នុងនោះតាវកាលិកថែទាំ និងព្យាបាលមានចំនួន ៨.២៤៥ នាក់ តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នមានចំនួន ៦.៥៤០ នាក់ និងតាវកាលិកផ្សេងៗទៀតមានចំនួន ២៧៤ នាក់។ បើប្រៀបធៀបនឹងឆ្នាំ២០១២ ការទាមទារតាវកាលិកមានតែចំនួន ១១.៩០២ នាក់ ដូច្នេះចំនួននេះមានការកើនឡើង ៣.១៥៧ នាក់ ត្រូវជា ២៦,៥២ ភាគរយ។ (ទិន្នន័យពីការទាមទារតាវកាលិកហានិភ័យការងារលំអិត សូមអានក្នុងតារាងទី៣ ខាងក្រោម)

*តារាងទី៣. ការទាមទារតាវកាលិកហានិភ័យការងារ*

| ល.រ | ប្រភេទតាវកាលិក | ចំនួន (នាក់) | ផ្សេងៗ |
|---|---|---|---|
| ១ | តាវកាលិកថែទាំ និងព្យាបាល | ៨.២៤៥ | |
| ២ | តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន | ៦.៥៤០ | |
| ៣ | តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្រោម ២០% (វិភាជន៍) | ៥១ | |
| ៤ | តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ចាប់ពី ២០% (ធនលាភ) | ៦០ | |
| ៥ | វិភាជន៍បូជាសព | ៩៨ | |
| ៦ | តាវកាលិកឧត្តរជីវី | ៦៣ | |
| ៧ | តាវកាលិកអ្នកចាំថែរក្សា | ២ | |
| **សរុប** | | **១៥.០៥៩** | |

## *២.៣.៥. ការចំណាយតាមប្រភេទតាវកាលិក*

តាមរយៈការទាមទារតាវកាលិកពីជនរងគ្រោះ នៅក្នុងឆ្នាំ២០១៣ កន្លងមកនេះ ប.ស.ស បានចេញសេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារដល់កម្មករនិយោជិតដែលរងគ្រោះថ្នាក់ការងារ សម្រាប់ការព្យាបាលនៅតាមមន្ទីរពេទ្យ និងសម្រាប់ការថែទាំ, ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន, បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍, វិភាជន៍បូជាសព, ឧត្តរជីវី, តាវកាលិកអ្នកចាំថែរក្សា និងសេវាបុននីតិសម្បទាសរុបចំនួន ***៩.៨០៦*** ឯកសារ ចំណាយអស់ទឹកប្រាក់ចំនួន ៦.៩២៦.២២៩.៣០០ រៀល។ ដោយឡែកនៅឆ្នាំ២០១៣ នេះផងដែរ ប.ស.ស បានទទួលប្រាក់សំណងមិនមែនគ្រោះថ្នាក់ការងារចំនួន ៣.៤៥០.៥០០ រៀល ដូច្នេះទូទាត់ជាមួយនឹង ការចំណាយតាវកាលិកខាងលើ នាំឲ្យការចំណាយតាវកាលិកជាក់ស្តែងសម្រាប់ឆ្នាំ២០១៣ មានចំនួន ***៦.៩២២.៧៧៨.៨០០*** រៀល។ បើប្រៀបធៀបទៅនឹងការចំណាយតាវកាលិកសម្រាប់ឆ្នាំ២០១២ មាន ៥.០៥៧.៧៩៥.៥០០ រៀល ដូចនេះការចំណាយតាវកាលិកនៅឆ្នាំ២០១៣ ការកើនឡើងចំនួន ១.៨៦៤.៩៨៣.៣០០ រៀល ត្រូវជា ៣៦.៨៧ ភាគរយ។*(ព័ត៌មានលំអិតអំពីការចំណាយតាមប្រភេទតាវកាលិក សូមអានក្នុងតារាងទី៤ ខាងក្រោម)*

*តារាងទី៤. ការចំណាយតាមប្រភេទតាវកាលិកហានិភ័យការងារ*

| ល.រ | ចំណាយតាមប្រភេទតាវកាលិក | ទឹកប្រាក់(រៀល) |
|---|---|---|
| ១ | តាវកាលិកថែទាំ និងព្យាបាល | ៥.២៥៤.៦៩៩.២០០ |
| ២ | តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន | ៧៦៦.៤៦៧.៧០០ |
| ៣ | តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្រោម ២០% (វិភាជន៍) | ១៤៣.០៩៣.៩០០ |

| | | |
|---|---|---|
| ៤ | តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី ២០% (ធនលាភ) | ១១៣.៨១២.៥០០ |
| ៥ | វិភាជន៍បូជាសព | ៣៩២.០០០.០០០ |
| ៦ | តាវកាលិកឧត្តរជីវី | ២៣៩.៨៣៤.៨០០ |
| ៧ | តាវកាលិកអ្នកចាំថែរក្សា | ៤.៣១០.០០០ |
| ៨ | សេវាបុននីតិសម្បទា | ១២.០១១.២០០ |
| **សរុប** | | ៦.៩២៦.២២៩.៣០០ |

ការកើនឡើងការចំណាយតាវកាលិកនេះ ដោយសារមានការកើនឡើងចំនួនសមាជិក នាំឲ្យកើនឡើងនូវចំនួនគ្រោះថ្នាក់ការងារ ការស្នើសុំតាវកាលិកមានការកើនឡើង ដែលនាំឲ្យការចំណាយមានការកើនឡើងស្របគ្នា។ មួយវិញទៀតការចំណាយតាវកាលិកមានការកើនឡើងច្រើនបែបនេះ ក៏ដោយសារករណីគ្រោះថ្នាក់ការងារធ្ងន់ធ្ងរ និងករណីស្លាប់មានការកើនឡើងផងដែរ ជាពិសេសគ្រោះថ្នាក់នៅពេលធ្វើដំណើរ ដែលគ្រាន់តែករណីស្លាប់តែមួយមានការចំណាយសម្រាប់វិភាជន៍បូជាសពកើនឡើងរហូតដល់ ១៥៦.០០០.០០០ លានរៀល។

## *២.៣.៦. ការទាមទារសំណងតាវកាលិកមិនមែនហានិភ័យការងារ*

តាមច្បាប់ជនរងគ្រោះដែលជាសមាជិកនៃ ប.ស.ស ទទួលរងគ្រោះថ្នាក់ការងារ ត្រូវទទួលបានការសម្រាកព្យាបាលដោយឥតគិតថ្លៃនៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរសម្រាកព្យាបាលឯកជន ដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស ប៉ុន្តែកន្លងមកក៏មានកម្មករនិយោជិតមួយចំនួនទទួលរងនូវគ្រោះថ្នាក់ដែលមិនមែនជាគ្រោះថ្នាក់ការងារ ហើយទៅទទួលការព្យាបាលនៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរសម្រាកព្យាបាលខាងលើ ដោយឥតបង់ប្រាក់ ហើយទុកឲ្យមន្ទីរពេទ្យទាំងនោះទូទាត់ជាមួយ ប.ស.ស ដែលករណីនេះជនរងគ្រោះ ត្រូវទូទាត់សងមក ប.ស.ស វិញតាមចំនួនជាក់ស្តែង។ ការអនុវត្តផ្ទុយពីគោលការណ៍ច្បាប់ខាងលើ នៅឆ្នាំ២០១៣ នេះ ប.ស.ស បានចេញលិខិតទាមទារតាវកាលិកដែលមិនមែនហានិភ័យការងារ និងបានទទួលប្រាក់សំណងព្យាបាលវេជ្ជសាស្ត្រចំនួន ៣.៤៥០.៥០០ រៀល ដោយមួយចំនួនបានទូទាត់ជាលក្ខណៈបង់ផ្តាច់ មួយចំនួនទូទាត់ជាដំណាក់កាល និងមួយចំនួនទៀតមិនទាន់ទាមទារបាន។

*តារាងទី៥. ការទាមទាសំណងតាវកាលិកមិនមែនហានិភ័យការងារ*

| ល.រ | បរិយាយ | ចំនួន | ទឹកប្រាក់(រៀល) | ផ្សេងៗ |
|---|---|---|---|---|
| ១ | ការចេញលិខិតទាមទារសំណង | ១៤៩ | ៤២.០៤៨.២០០ | |
| ២ | បានទទួលសំណងព្យាបាល | ៥៧ | ៣.៤៥០.៥០០ | |
| ៣ | សំណងដែលមិនទាន់ទាមទារបាន | ៣១ | ៧.៤០៧.៥០០ | |

## ៣. ការរៀបចំដាក់ឲ្យអនុវត្តរបបធានារ៉ាប់រងសុខភាព

បន្ទាប់ពីបានអនុវត្តដោយជោគជ័យនូវជំហានទី១ របបធានារ៉ាប់រងហានិភ័យការងារ និងដោយយោងទៅលើស្ថានភាពរីកចំរើននៃសេដ្ឋកិច្ចជាតិ ដែលក្នុងនោះមានការកើនឡើងជាច្រើននូវការវិនិយោគក្នុងប្រទេស និងកម្មករនិយោជិតដែលបម្រើការងារនៅតាមបណ្ដាសហគ្រាស គ្រឹះស្ថាន ហើយដែលការរីកចំរើននេះទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់អំពីបញ្ហាលក្ខខណ្ឌការងារ ជាពិសេសបញ្ហាសុខភាពរបស់កម្មករនិយោជិត ជាក់ស្ដែងនាប៉ុន្មានឆ្នាំចុងក្រោយនេះមានបាតុភាពករណីដួលសន្លប់កម្មករនិយោជិតនៅក្នុងសហគ្រាស គ្រឹះស្ថាន តាមបណ្ដារាជធានី-ខេត្តមួយចំនួន ដែលករណីនេះមួយចំនួនធំត្រូវបានរកឃើញថាមានការពាក់ព័ន្ធទៅនឹងបញ្ហាសុខភាពផ្ទាល់របស់កម្មករនិយោជិត។ ក្រៅពីករណីសន្លប់ក៏នៅមានករណីគ្រោះថ្នាក់កម្មករនិយោជិតជាច្រើនទៀត ដែលមិនមែនជាគ្រោះថ្នាក់ការងារ បានទៅទទួលសេវាព្យាបាលនៅតាមមន្ទីរពេទ្យដែលបានចុះកិច្ចសន្យា ក៏ដូចជាបានរាយការណ៍ និងមិនបានរាយការណ៍មកបេឡាជាតិរបបសន្តិសុខសង្គម ទាក់ទងទៅនឹងបញ្ហាសុខភាពស្ថិតនៅក្នុងស្ថានភាពមួយគួរឲ្យព្រួយបារម្ភ។ ស្ថានភាពទាំងនេះបានធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះជីវភាពកម្មករនិយោជិត ដែលជាជនរងគ្រោះ ដែលត្រូវទទួលបន្ទុកចំណាយថវិកាក្នុងការព្យាបាលខ្លួន ហើយស្ថានភាពនេះវានឹងមានផលប៉ះពាល់កាន់តែខ្លាំងថែមទៀត បើសិនជាមានគ្រោះថ្នាក់ ឬ បញ្ហាសុខភាពរហូតដល់បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ឬ បាត់បង់ជីវិតនោះ ដល់គ្រួសាររបស់ជនរងគ្រោះ និងសង្គមទាំងមូល ដែលត្រូវទទួលបន្ទុកថែទាំជនពិការ ប្ដី/ប្រពន្ធ កូន ឬជនចាស់ជរាក្នុងបន្ទុកផងដែរ។

របបធានារ៉ាប់រងសុខភាពនេះ មានលក្ខណៈជាកាតព្វកិច្ច គ្របដណ្ដប់លើកម្មករនិយោជិតទាំងអស់ដែលកំណត់ដោយច្បាប់ស្ដីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមច្បាប់ស្ដីពីការងារ។ បច្ចុប្បន្នបេឡាជាតិរបបសន្តិសុខសង្គម បានទទួលយក និងកំពុងដំណើរការគម្រោងធានារ៉ាប់រងសុខភាពដោយស្ម័គ្រចិត្តសម្រាប់កម្មកររោងចក្ររបស់អង្គការ HIP ដែលគម្រោងនេះគ្របដណ្ដប់លើសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនជនរងគ្រោះ សេវាបញ្ជូនសព និងការផ្ដល់ប្រាក់បំណាច់ប្រចាំថ្ងៃ។

### ៣.១. ការរៀបចំបែបបទ និងនីតិវិធីការងារ

ការត្រៀមរៀបចំអនុវត្តជំហានទី២ របបធានារ៉ាប់រងសុខភាពកន្លងមក បេឡាជាតិរបបសន្តិសុខសង្គម បានបង្កើតក្រុមការងាររៀបចំដាក់ឲ្យដំណើរការរបបធានារ៉ាប់រងសុខភាព តាមរយៈក្រុមការងារនេះ ការត្រៀមរៀបចំអនុវត្តការងារ សម្រេចបានលទ្ធផលគួរឲ្យកត់សំគាល់ លើការរៀបចំលិខិតបទដ្ឋានគតិយុត្ត បែបបទ និងនីតិវិធីការងារបានមួយចំនួន។ ក្រៅពីក្រុមការងារនេះ បេឡាជាតិរបបសន្តិសុខសង្គម បានបង្កើតឲ្យមានគណៈកម្មការរៀបចំយន្តការនៃការទូទាត់សេវាសុខាភិបាល ដែលមានការចូលរួមពីក្រសួងសុខាភិបាល ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងកំណត់ជ្រើសរើសយកយន្តការទូទាត់ថ្លៃសេវាសុខាភិបាល, តម្លៃសេវាមូលដ្ឋានសុខាភិបាល, យន្តការត្រួតពិនិត្យគុណភាពសេវា និងបែបបទទទួលបានសេវាដល់សមាជិក ប.ស.ស ដើម្បីដាក់ឲ្យដំណើរការពេញលេញនា ឆ្នាំ២០១៤ នេះ។ នៅក្នុងការរៀបចំនេះផងដែរ

ប.ស.ស ក៏បានធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធនានា ដោយបានចុះអនុស្សរណៈយោគយល់គ្នា សម្រាប់រៀបចំមូលនិធិអភិវឌ្ឍន៍ ការវាយតម្លៃ និងផ្សព្វផ្សាយគម្រោងថែទាំសុខភាព និងបានរៀបចំប្រជុំពិភាក្សា លើការទទួលស្គាល់គុណភាពសេវាសុខាភិបាល, ការកំណត់អត្តសញ្ញាណប័ណ្ណជនជាតិខ្មែរសម្រាប់សមាជិក ប.ស.ស, ការរៀបចំចាត់ថ្នាក់ប្រភេទជម្ងឺតាមក្រុមនីមួយៗ, ការវាយតម្លៃសេវានៅតាមមូលដ្ឋានសុខាភិបាល, ការអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យា និងការងារសំខាន់ៗមួយចំនួនទៀត។

### ៣.២. ការអនុវត្តគម្រោងធានារ៉ាប់រងសុខភាព (ប.ស.ស-HIP)

នៅក្នុងដំណាក់កាលដំបូង នៃការអនុវត្តសាកល្បងគម្រោងធានារ៉ាប់រងសុខភាព សម្រាប់កម្មកររោងចក្រ អត្រាភាគទានស្មើនឹង ១,៦ (មួយក្បៀសប្រាំមួយដុល្លាអាមេរិក)។ ក្នុងចំណោមរោងចក្រចំនួន ១១ ដែលបានចុះបញ្ជិកា មានរោងចក្រចំនួន ០៣ បានបង់ភាគទានជូនកម្មករនិយោជិតទាំងអស់ ១០០ ភាគរយ និងរោងចក្រចំនួន ០៨ ទៀតបានចូលរួមបង់ភាគទានពាក់កណ្តាលស្មើនឹង ៥០ ភាគរយ និងកម្មករនិយោជិតបង់ ៥០ ភាគរយ (និយោជកបង់ ០.៨ ដុល្លា និងកម្មករនិយោជិតបង់ ០.៨ ដុល្លា)។

ក្នុងចំណោមរោងចក្រ១១ ដែលបានចុះបញ្ជិកានៅ ប.ស.ស មានកម្មករនិយោជិតសរុបចំនួន ៧.៧៣៣ នាក់ ដែលគិតចាប់ពីដើមខែតុលា ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ប.ស.ស បានផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ ដល់សមាជិកសរុបចំនួន ២.៥៦៤ ដង.នាក់។ *(ព័ត៌មានលំអិតសូមអាននៅក្នុងតារាងទី៦ ខាងក្រោម)*

*តារាងទី៦. ប្រភេទ និងចំនួនអ្នកប្រើប្រាស់សេវាសម្រាប់គម្រោងធានារ៉ាបរងសុខភាពសាកល្បង*

| ប្រភេទសេវា | ចំនួនប្រើប្រាស់ |
|---|---|
| ចំនួនអ្នកប្រើប្រាស់សេវាសរុប (Number of Contact) | ២.៥៦៤ |
| សម្រាកនៅពេទ្យ (IPD) | ៨១ |
| ពិគ្រោះជម្ងឺក្រៅ (OPD) | ២.៤៣០ |
| សម្រាលកូន (Delivery) | ២៣ |
| រលូតកូន (Abortion) | ៣០ |

ដើម្បីអោយកម្មករនិយោជិតជាសមាជិក នៃគម្រោងធានារ៉ាប់រងសុខភាព ទទួលបាននូវការព្យាបាល និងសេវាសង្គ្រោះ បានទាន់ពេលវេលា ប.ស.ស បានដាក់ឲ្យប្រើប្រព័ន្ធទូរស័ព្ទបន្ទាន់លេខ ០១១ ៧៩៩ ៤៣០ និងដាក់ភ្នាក់ងារប្រចាំការ នៅតាមមន្ទីរពេទ្យចំនួន ០៥ ដែលបានចុះកិច្ចសន្យាជាមួយគម្រោងនេះ រួមមានមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត, មន្ទីរពេទ្យព្រះកុសុមៈ, មណ្ឌលសុខភាពស្ទឹងមានជ័យ, មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង និងមណ្ឌលសុខភាពទួលគោក ដើម្បីជួយសម្របសម្រួលការងារបានទាន់ពេលវេលា។ មួយវិញទៀត សមាជិកទាំងអស់ក៏អាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទទំនាក់ទំនងបន្ទាន់ ១២៨៦ ក្នុងករណីសង្គ្រោះបន្ទាន់ ដើម្បីភ្ជាប់ទៅអ្នកសម្របសម្រួលផ្នែកធានារ៉ាប់រងសុខភាព ក្នុងករណីទូរស័ព្ទខាងលើមានបញ្ហាដោយមូលហេតុណាមួយ។

# ៤. ការងារគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស

## ៤.១. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

### *៤.១.១. ការងាររដ្ឋបាល*

ការងាររដ្ឋបាល មានតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងឯកសារ ការផ្គត់ផ្គង់ និងការគ្រប់គ្រងមន្ត្រី បុគ្គលិក ដើម្បីធានាបាននូវការអនុវត្តបទបញ្ជាផ្ទៃក្នុងអោយមានប្រសិទ្ធភាព និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងធានាបាននូវការងារគ្រប់គ្រងសំខាន់ៗមួយចំនួនទៀតរបស់អង្គភាព ជាអាទិ៍នៅឆ្នាំ២០១៣ នេះសម្រេចបានៈ

- រៀបចំការបង់ប្រាក់ភាគទានហានិភ័យការងារសម្រាប់បុគ្គលិកជាប់កិច្ចសន្យា។
- រៀបចំដំឡើងកាំប្រាក់កម្រៃលើកទឹកចិត្តជូនមន្ត្រីរាជការចំនួន ០៨ រូប និងបុគ្គលិកជាប់កិច្ចសន្យាចំនួន ២៣ រូប។
- រៀបចំប័ណ្ណសរសើរជូនមន្ត្រីរាជការចំនួន ២១ ប័ណ្ណ និងគ្រឿងឥស្សរយសចំនួន ២២ គ្រឿង។
- រៀបចំតំឡើងកម្រិតមុខងារជូនមន្ត្រីរាជការចំនួន ០៦ រូប។
- រៀបចំប្រជុំវាយតម្លៃបន្តកិច្ចសន្យាបុគ្គលិកចំនួន ១១១ រូប។
- រៀបចំតំឡើងប្រាក់កម្រៃលើកទឹកចិត្តជូនមន្ត្រីកម្មសិក្សាចំនួន ១១ រូប ដែលបានតាំងស៊ប់។
- រៀបចំកែសម្រួលឋានន្តរស័ក ថ្នាក់សន្ទស្សន៍ បៀវត្សរមូលដ្ឋានជូនមន្ត្រីរាជការចំនួន ០៣ រូប។
- រៀបចំប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការសម្រាប់ឆ្នាំ២០១៤ ចំនួន ១៦៩ រូប។
- រៀបចំប្រាក់កម្រៃលើកទឹកចិត្តអោយស្របតាមឋានន្តរស័ក្តចំនួន ២៣ រូប។
- រៀបចំប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការចំនួន ៣៣ រូប និងកែសម្រួលឋានន្តរស័កថ្នាក់សន្ទស្សន៍បៀវត្សរមូលដ្ឋានមន្ត្រីរាជការចំនួន ០៣ រូប។
- រៀបចំតម្លើងថ្នាក់សម្រាប់បុគ្គលិកចំនួន ៤០ រូប។
- រៀបចំតំឡើងស្លាកការិយាល័យ ប.ស.ស ខេត្តចំនួន ០៧។
- បោះពុម្ពលិខិតបញ្ជាក់ការបង់ភាគទានហានិភ័យការងារចំនួន ៥០០ ក្បាល។
- រៀបចំបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះសម្រាប់ឆ្នាំ២០១៣។
- រៀបចំទូទាត់ថ្លៃជួលអាគារ និងឧបត្ថម្ភថ្លៃប្រើប្រាស់ទឹក និងអគ្គិសនីស្នាក់ការ ប.ស.ស តាមខេត្ត។
- ត្រួតពិនិត្យវត្តមាន និងតាមដានសកម្មភាពការងារបុគ្គលិក និងមន្ត្រី តាមរយៈឧបករណ៍ពិនិត្យស្នាមម្រាមដៃ (Finger Print) និងម៉ាស៊ីនថតសកម្មភាព។
- បែងចែក និងផ្គត់ផ្គង់សម្ភារៈការិយាល័យ។

### *៤.១.២. ការងារហិរញ្ញវត្ថុ*

ការងារគណនេយ្យ និងហិរញ្ញវត្ថុរបស់បេឡាជាតិរបបសន្តិសុខសង្គម ប្រតិបត្តិការតាមរយៈប្រព័ន្ធធនាគារទាំងស្រុង ពោលគឺរាល់កិច្ចដំណើរការនៃការគ្រប់គ្រងចំណូល និងចំណាយ មានជាអាទិ៍ ការប្រមូលភាគទានពីសហគ្រាស គ្រឹះស្ថាន ការចំណាយតាវកាលិកដល់កម្មករនិយោជិតដែលរងហានិភ័យ

ការងារ និងការចំណាយរដ្ឋបាល ត្រូវបានប្រព្រឹត្តទៅដោយឆ្លងកាត់តាមប្រព័ន្ធធនាគារ។ ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាព និងគណនេយ្យភាព ក្នុងដំណើរការនៃកិច្ចប្រតិបត្តិការ បេឡាជាតិរបបសន្តិសុខសង្គម បានអនុវត្តនូវការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- កត់ត្រាចំណូលភាគទានប្រចាំខែ ដែលបានមកពីការបង់ភាគទានរបស់សហគ្រាស គ្រឹះស្ថាន។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៣ និងគម្រោងថវិកាប្រចាំឆ្នាំ២០១៤។
- កត់ត្រាចំណាយប្រចាំខែ សម្រាប់ថ្លៃព្យាបាលនៅតាមមន្ទីរពេទ្យនីមួយៗ, តាវកាលិកធនលាភរបស់សមាជិក ប.ស.ស និងចំណាយផ្សេងៗ។
- រៀបចំអត្រាប្តូរប្រាក់ សំរាប់ការបង់ភាគទានប្រចាំខែនីមួយៗ។
- ត្រួតពិនិត្យចំណាយផ្សេងៗដូចជា ចំណាយបេសកកម្ម ចំណាយរដ្ឋបាល ចំណាយបង្ការហានិភ័យការងារ និងចំណាយតាវកាលិក។
- រៀបចំបញ្ជីបើកប្រាក់បៀវត្សរប្រចាំខែនីមួយៗ។
- សហការជាមួយគណៈប្រតិភូ នៃអាជ្ញាធរសវនកម្មជាតិ ដែលចុះធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋសម្រាប់ឆ្នាំ២០១២ និងឆ្នាំពាក់ព័ន្ធ។

### ៤.២. ការងារផ្សព្វផ្សាយ

ការងារផ្សព្វផ្សាយជាការងារមួយដ៏សំខាន់ ដែលបេឡាជាតិរបបសន្តិសុខសង្គមបានយកចិត្តទុកដាក់ខ្ពស់ ដោយក្នុងនោះបានរៀបចំនូវផែនការផ្សព្វផ្សាយសាធារណៈជាច្រើន ដើម្បីផ្សព្វផ្សាយពីលទ្ធផលការងារដែលសម្រេចបាន ការពង្រីកវិសាលភាពតាមបណ្តារាជធានី-ខេត្ត និងការពង្រឹងការអនុវត្តបន្ថែមជាមួយផ្នែកពាក់ព័ន្ធ រួមមានជាមួយនិយោជក តំណាងកម្មករនិយោជិត អង្គការសហជីព អង្គភាពផ្តល់សេវាសុខាភិបាល អង្គការក្រៅរដ្ឋាភិបាល និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ដើម្បីអោយទទួលបានព័ត៌មានថ្មីៗពីការអនុវត្តគោលនយោបាយសន្តិសុខសង្គម និងអោយមានការចូលរួមទាំងអស់គ្នា។ ជាការគួរឲ្យកត់សំគាល់នៅក្នុងឆ្នាំ២០១៣ កន្លងមកនេះ ការងារផ្សព្វផ្សាយមួយចំនួនត្រូវបានអនុវត្តដូចខាងក្រោម៖

- ប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១២ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៣ របស់បេឡាជាតិរបបសន្តិសុខសង្គម។
- ប្រជុំផ្សព្វផ្សាយពង្រីកវិសាលភាពរបបធានារ៉ាប់រងហានិភ័យការងារចំនួន ០៤ ខេត្ត រួមមានខេត្តរតនគិរី មណ្ឌលគិរី ឧត្តរមានជ័យ និងខេត្តព្រះវិហារ។
- សហការជាមួយនាយកដ្ឋានពេទ្យការងារ និងគណៈកម្មការ ស.ទ.ប.ក រៀបចំទិវាជាតិដើម្បីសុខភាព សុវត្ថិភាពការងារ ក្រោមប្រធានបទ "លើកកម្ពស់សុវត្ថិភាពអគ្គីភ័យ និងការបង្ការគ្រោះថ្នាក់ការងារនៅកម្ពុជា" នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។
- រៀបចំប្រជុំពិភាក្សាជាមួយសហគ្រាស គ្រឹះស្ថាន ដើម្បីត្រៀមរៀបចំកិច្ចប្រជុំផ្សព្វផ្សាយណែនាំអប់រំ នៅនឹងកន្លែងការងារ ចាប់ពីត្រីមាសទី២ នៅខែមេសា ឆ្នាំ២០១៣។

- ប្រជុំផ្សព្វផ្សាយ ស្តីពីការពង្រឹងការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ នៅខេត្តព្រះសីហនុ និងខេត្តស្វាយរៀង។
- រៀបចំប្រជុំជាមួយមន្ទីរពេទ្យ និងសហជីពស្តីពីនីតិវិធីនៃការផ្តល់តាវកាលិក និងការផ្តល់សេវានៅតាមមន្ទីរពេទ្យ។

*រូបភាពទី៣. កិច្ចប្រជុំផ្សព្វផ្សាយស្តីពីនីតិវិធីនៃការផ្តល់តាវកាលិក និងការផ្តល់សេវានៅតាមមន្ទីរពេទ្យ រវាងភាគីបេឡាជាតិរបបសន្តិសុខសង្គម មន្ទីរពេទ្យ និងតំណាងសហជីព (នៅសាលប្រជុំ ប.ស.ស ថ្ងៃទី៣០ មេសា ២០១៣)*



- ធ្វើព្រឹត្តិបត្រ និងខិត្តប័ណ្ណស្តីពីការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ។
- រៀបចំឯកសារសម្រាប់ចុះបញ្ជិកា និង CD ឯកសារ។
- ទទួលទូរស័ព្ទ និងផ្តល់ព័ត៌មានជូនភ្ញៀវ។

ក្រៅពីការងារផ្សព្វផ្សាយខាងលើ ប.ស.ស ក៏មានគេហទំព័រ (www.nssf.gov.kh) ដែលផ្ទុកនូវរាល់ព័ត៌មាន និងឯកសារគតិយុត្តសំខាន់ៗ ទាក់ទងនឹងការអនុវត្តគោលនយោបាយធានារ៉ាប់រងហានិភ័យការងាររបស់បេឡាជាតិរបបសន្តិសុខសង្គម។ មួយវិញទៀត ប.ស.ស ក៏បានធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតជាច្រើនផងដែរ និងចាត់បញ្ជូនមន្ត្រីអោយចុះធ្វើការផ្សព្វផ្សាយ ពន្យល់ណែនាំដល់បណ្តាសហគ្រាស គ្រឹះស្ថានផ្ទាល់ ឲ្យយល់ពីការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ ពិសេសពីនីតិវិធី និងបែបបទនៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម និងតាវកាលិក (អត្ថប្រយោជន៍) ដែលកម្មករនិយោជិតត្រូវទទួលបាន។

## ៤.៣. កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្ស

កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្ស ជាការងារមួយសំខាន់នៅក្នុងការអភិវឌ្ឍន៍អង្គភាព និងពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងផ្នែកដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីធានានូវនិរន្តរភាពនៃកិច្ចដំណើរការរបស់អង្គភាព លើការរៀបចំផែនការ បែបបទ និងនីតិវិធីការងារ ក៏ដូចជាការអភិវឌ្ឍន៍នូវចំណេះដឹង ការដកស្រង់ និងផ្លាស់ប្តូរបទពិសោធន៍

ការងារថ្មីៗ។ កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស ក៏ជាការចូលរួមចំណែកនៅក្នុងសកម្មភាពការងារសង្គមទាំងមូលឲ្យមានការរីកចម្រើនផងដែរ ដែលនៅក្នុងឆ្នាំ២០១៣ កន្លងមកនេះ ថ្នាក់ដឹកនាំក៏ដូចជាមន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម បានចូលរួមនៅក្នុងការរៀបចំកម្មវិធីអភិវឌ្ឍ កិច្ចប្រជុំពិភាក្សាផ្តល់យោបល់ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនៈកិច្ចសិក្សាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស បានមួយចំនួនគួរឲ្យកត់សំគាល់។

### ៤.៣.១. *ការងារក្នុងប្រទេស*

កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេស បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី ពីការងាររដ្ឋបាល ការងារហិរញ្ញវត្ថុ ការធ្វើសវនកម្ម និងប្រព័ន្ធនៃការគ្រប់គ្រងទូទៅ ជារៀងរាល់ឆ្នាំ។ ក្រៅពីនេះថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកនៃបេឡាជាតិរបបសន្តិសុខសង្គម ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ពិភាក្សាការងារ ការរៀបចំផែនការអភិវឌ្ឍន៍ និងសិក្ខាសាលាបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងតាមបណ្តាក្រសួង អង្គការ និងស្ថាប័នពាក់ព័ន្ធនានានៅទូទាំងប្រទេសបានមួយចំនួនផងដែរ។

*រូបភាពទី៤. វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី ស្តីពីកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើជំនាញគណនេយ្យ និងហិរញ្ញវត្ថុ (នៅបេឡាជាតិរបបសន្តិសុខសង្គម ថ្ងៃទី១៨ ខែកុម្ភៈ ដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣)*





- ចូលរួមប្រជុំរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្តីការក្រសួង។
- ចូលរួមប្រជុំក្រុមការងារបណ្តោះអាសន្ន នៃកិច្ចគាំពារសង្គមនៅក្រសួងមហាផ្ទៃ។
- ចូលរួមប្រជុំស្តីពីការរៀបចំរបៀបវារៈសម្រាប់កិច្ចប្រជុំ SLOM លើកទី៩ នៅទីស្តីការក្រសួង។
- ចូលរួមប្រជុំជាមួយ UNDP ស្តីពីការផ្តល់តាវកាលិកដល់ជនរងគ្រោះ និងអ្នកនៅក្នុងបន្ទុក។
- ចូលរួមក្នុងពិធីសំណេះសំណាលជាមួយកម្មករ កម្មការិនី ក្នុងខួបអនុស្សាវរីយ៍លើកទី ១២៧ នៃទិវាពលកម្មអន្តរជាតិ នៅខេត្តព្រះសីហនុ។

- ចូលរួមកិច្ចប្រជុំពិភាក្សាលើការដោះស្រាយបញ្ហាបាតុកម្ម កូដកម្ម និងលើកទិសដៅអនុវត្តបន្ត នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ អំពីគោលនយោបាយផ្តល់កញ្ចប់ភាគផលមូលនិធិសមធម៌ សុខាភិបាល នៅសណ្ឋាគារគ្រីនផាលែសភ្នំពេញ។
- ចូលរួមប្រជុំស្តីពីការពិនិត្យមើលឡើងវិញលើលទ្ធផលការងារ នៃការអនុវត្តផែនការទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅទីស្តីការក្រសួង។
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងទិវាពិភពលោកប្រឆាំងពលកម្មកុមារឆ្នាំ២០១៣ និងពិធីសម្ពោធគម្រោងប្រឆាំងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ(២០១៣-២០១៦) នៅទីស្តីការក្រសួង។
- ចូលរួមប្រជុំបើកការធ្វើអធិការកិច្ច ដោយប្រតិភូអគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០១១ និងបណ្តាឆ្នាំពាក់ព័ន្ធ។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិលើកទី៣ ស្តីពីគោលនយោបាយជាតិមុខរបរ និងការងារសម្រាប់ប្រទេសកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។
- ចូលរួមសិក្ខាសាលា ស្តីពីការជំរុញសមធម៌ និងការគាំពារសង្គមនៅទីស្តីការគណៈរដ្ឋមន្ត្រី។
- ចូលរួមសិក្ខាសាលាស្តីពី ការធ្វើសមាហរណកម្មគោលនយោបាយសង្គម និងការផ្តល់មូលដ្ឋានគ្រឹះនៃការគាំពារសង្គម នៅខេត្តសៀមរាប។
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដល់មន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌថ្មី នៅអគាររតនាផ្លាហ្សា។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៤-២០១៨ នៅសណ្ឋាគារភ្នំពេញ។
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីរបាយការណ៍ជាតិលើកទី៤ និងទី៥ នៃការអនុវត្តអនុសញ្ញាស៊ី-ដនៅកម្ពុជា, ពិធីសារតាមជម្រើស, អនុសាសន៍សម្តេចតេជោនាយករដ្ឋមន្ត្រី, ការលើកកម្ពស់សិទ្ធិស្ត្រីផ្សព្វផ្សាយស្រាបៀរ, ច្បាប់ពាក់ព័ន្ធ និងបទដ្ឋានគតិយុត្តវិស័យសាធារណៈនៅទីស្តីការក្រសួង។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការស្វែងរកការគាំទ្រមតិ និងជំនាញសម្របសម្រួល។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការតាមដាន និងវាយតម្លៃលើការប្រើប្រាស់សៀវភៅស្តីពីការអប់រំជំងឺអេដស៍។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីថវិកាកម្មវិធីជំហានទី៣ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពថ្នាក់ដឹកនាំសហជីព(ទីប្រឹក្សាកម្មករ)។
- ចូលរួមសិក្ខាសាលាស្តីពីស្ថិតិការងារដកស្រង់ចេញពីកំណត់ត្រារដ្ឋបាល។

ក្រៅពីការងារខាងលើ បេឡាជាតិរបបសន្តិសុខសង្គម ក៏បានចាត់បញ្ជូនមន្ត្រី និងបុគ្គលិកឲ្យចូលរួមនៅក្នុងសកម្មភាពការងារសង្គមមួយចំនួនទៀតផងដែរ ដើម្បីចូលរួមចំណែកនៅក្នុងការអភិវឌ្ឍន៍សង្គមជាតិទាំងមូល។

### ៤.៣.២. *ការងារក្រៅប្រទេស*

ក្រៅពីការងារលើកកម្ពស់ធនធានមនុស្ស និងកិច្ចសហប្រតិបត្តិការក្នុងប្រទេស ការទំនាក់ទំនងក្រៅប្រទេសជាការងារមួយដ៏សំខាន់ នៅក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍបរទេសនានា និងការធ្វើសមាហរណកម្មវិស័យសន្តិសុខសង្គមរបស់កម្ពុជាទៅក្នុងតំបន់ ដើម្បីឲ្យមានការផ្លាស់ប្តូរនូវបទពិសោធន៍ បច្ចេកទេសការងារថ្មីៗ យកមកធ្វើការអភិវឌ្ឍន៍នៅក្នុងប្រទេស។ ដែលនៅឆ្នាំ២០១៣នេះ បេឡាជាតិរបបសន្តិសុខសង្គម បានបំពេញនូវការងារក្រៅប្រទេសសំខាន់ៗមួយចំនួន សម្រាប់វិស័យសន្តិសុខសង្គមដូចខាងក្រោមៈ

- ចូលរួមសិក្ខាសាលា ដើម្បីតាមដានលទ្ធផលសម្រេចបានពីការចូលរួមវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំអន្តរជាតិស្តីពីសន្តិសុខសង្គម នៅទីក្រុងហាណូយ ប្រទេសវៀតណាម។
- ចូលរួមសិក្ខាសាលាស្តីពីសេវាកម្មត្រួតពិនិត្យ និងវាយតម្លៃលើការធានារ៉ាប់រងសុខភាព (HIRA) នៅប្រទេសកូរ៉េ។
- ចូលរួមសិក្ខាសាលា ស្តីពីប្រព័ន្ធសោធននិវត្តន៍អាស៊ាន នៅប្រទេសឥណ្ឌូនេស៊ី។
- ចូលរួមវគ្គបណ្តុះបណ្តាលការធានារ៉ាប់រងសុខភាពកូរ៉េ(NHIS) នៅសាធារណៈរដ្ឋកូរ៉េ។
- ចូលរួមវេទិកាអាស៊ានស្តីពីភាពក្រីក្រ វិសមភាព និងការគាំពារសង្គម នៅប្រទេសឥណ្ឌូនេស៊ី។
- ទស្សនៈកិច្ចសិក្សានៅប្រទេសចិន ស្តីពីប្រព័ន្ធសុខភាព និងការកែទម្រង់។
- ចូលរួមសិក្ខាសាលាជាន់ខ្ពស់អាស៊ាន-ចិន ស្តីពីស្តង់ដារសេវាកម្មសន្តិសុខសង្គម នៅប្រទេសចិន។
- ចូលរួមកិច្ចប្រជុំសមាគមសន្តិសុខសង្គមអាស៊ាន(ASSA) លើកទី៣០ នៅទីក្រុងវៀងច័ន្ទ សាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ។
- ចូលរួមសិក្ខាសាលាបច្ចេកទេសរៀបចំដោយ AWCF ស្តីពីបញ្ហាទូទាត់សំណងកម្មករនិយោជិតតំបន់អាស៊ីប៉ាស៊ីហ្វិក នៅសាធារណៈរដ្ឋកូរ៉េ។
- ទស្សនកិច្ចសិក្សាស្តីពីការធានារ៉ាប់រងសុខភាពនៅទីក្រុងហាណូយ ប្រទេសវៀតណាម។
- ចូលរួមទស្សនកិច្ចសិក្សាស្តីពី សេវាកម្មប្រាក់សោធនជាតិនៃសាធារណៈរដ្ឋកូរ៉េ(NPS)។
- ទស្សនកិច្ចសិក្សាថ្នាក់មន្ត្រីជាន់ខ្ពស់ ដើម្បីពិនិត្យមើលពីការកែទម្រង់ និងប្រព័ន្ធសុខាភិបាលនៅសាធារណៈរដ្ឋប្រជាមានិតចិន។

## ៤.៤. ការងារព័ត៌មានវិទ្យា

បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រតិបត្តិការងារ និងការគ្រប់គ្រងទិន្នន័យតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យា លើការងារចុះបញ្ជិកា បង់ភាគទាន ការផ្តល់តាវកាលិក ការងារអធិការកិច្ច ការគ្រប់គ្រងវត្តមានមន្ត្រី បុគ្គលិក និងការងារសំខាន់ៗមួយចំនួនទៀត ជាក់ស្តែងនៅឆ្នាំ២០១៣ កន្លងមកនេះ ប.ស.ស សម្រេចបានលើការងារព័ត៌មានវិទ្យាដូចខាងក្រោមៈ

- កែសម្រួល ធ្វើបច្ចុប្បន្នភាព និងថែទាំប្រព័ន្ធគ្រប់គ្រងការទាមទារតាវកាលិកហានិភ័យការងារ។

- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្នែកអធិការកិច្ចដែលមានលក្ខណៈជា Web Application អាចប្រើប្រាស់បានជាមួយ Computer Smart Phone និង Tablet តាមរយៈInternet និង Intranet។
- បង្កើតប្រព័ន្ធគ្រប់គ្រងថ្មីផ្នែកចុះបញ្ជិកា និងបង់ភាគទាន។
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យតាវកាលិក(NSSF Benefits)។
- បង្កើតកម្មវិធី NSSF Admin សម្រាប់ប្រើប្រាស់ក្នុងការិយាល័យរដ្ឋបាល ក្នុងការគ្រប់គ្រងទិន្នន័យបេសកកម្មរបស់មន្ត្រី និងបុគ្គលិក។
- បង្កើតកម្មវិធីទទួលសារ ផ្ញើសារ និងឆ្លើយតបដោយស្វ័យប្រវត្តិតាមរយៈ Modem (NSSF SMS)។
- រៀបចំកម្មវិធីបញ្ចូលទិន្នន័យរបស់មន្ទីរពេទ្យជាប់កិច្ចសន្យា។
- បង្កើតប្រព័ន្ធទទួល និងដោះស្រាយព័ត៌មាន (Complaint System)។
- ធ្វើបច្ចុប្បន្នភាពគេហទំព័រ ប.ស.ស ដោយបន្ថែមភាសាខ្មែរ និងភាសាអង់គ្លេស។
- បង្កើតប្រព័ន្ធ SMS System សម្រាប់ផ្ទៀងផ្ទាត់លេខអត្តសញ្ញាណកម្មករនិយោជិត។
- កែលំអគេហទំព័រ និងបញ្ចូលអត្រាប្តូរប្រាក់ប្រចាំខែ ព្រឹត្តិបត្រព័ត៌មាន សេចក្តីជូនដំណឹង និងព័ត៌មានមួយចំនួនទៀតលើគេហទំព័រ បេឡាជាតិរបបសន្តិសុខសង្គម។
- ធ្វើបច្ចុប្បន្នភាពទម្រង់សម្រាប់បញ្ចូលប្រាក់បៀវត្សកម្មករម្នាក់ៗចូលប្រព័ន្ធ។
- ធ្វើបច្ចុប្បន្នភាពទម្រង់កែប្រែលិខិតភាគទានតាមទម្រង់ថ្មី។
- សរសេរកម្មវិធីប្រើប្រាស់ E-Form ថ្មីសម្រាប់របបធានារ៉ាប់រងសុខភាព។
- ធ្វើបច្ចុប្បន្នភាព ទម្រង់បង់ភាគទានឲ្យមានការបង់ប្រាក់ពិន័យ។
- បង្កើត Function Import/Export នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យថ្មីសម្រាប់ធ្វើការ Import និង Export ទិន្នន័យពី File Excel និង File Access ទៅក្នុងប្រព័ន្ធ។
- វិភាគ និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យថ្មី សម្រាប់រក្សាទុកទិន្នន័យ ដោយប្រើប្រាស់កម្មវិធី Microsoft SQL Server 2008 ។
- ធ្វើបច្ចុប្បន្នភាពភាគទានកម្មករនិយោជិតផ្នែកគ្រោះថ្នាក់ការងារ និងផ្នែកធានារ៉ាប់រងសុខភាព។
- រៀបចំ Database ឲ្យមាន Record ប្រវត្តិកម្មករនិយោជិត កាលបរិច្ឆេទចូលធ្វើការ កាលបរិច្ឆេទឈប់ធ្វើការ និងការផ្លាស់ប្តូរសហគ្រាស គ្រឹះស្ថាន។
- រៀបចំ Database ឲ្យមាន Record ប្រវត្តិសហគ្រាស គ្រឹះស្ថានបង់ភាគទាន និងប្រវត្តិបិទបើកសហគ្រាស គ្រឹះស្ថាន។
- ដំឡើងឧបករណ៍ Cisco តាមបណ្តាខេត្តមួយចំនួនដើម្បីភ្ជាប់ Database មកទីស្នាក់ការកណ្តាល។
- រៀបចំកម្មវិធីការិយាល័យសាខាខេត្តប្រើប្រាស់ និងកំណត់ពីកម្រិតប្រើប្រាស់របស់សមាជិក។
- ធ្វើបច្ចុប្បន្នភាព Database លើទិន្នន័យ ID របស់សហគ្រាស និងកម្មករនិយោជិត។
- បង្កើតទម្រង់បញ្ចូលប្រាក់ខែកម្មករនិយោជិត។
- អភិវឌ្ឍន៍កម្មវិធីសម្រាប់តាមដានការបង់ភាគទានរបស់សហគ្រាស។

- បញ្ចូលស្នាមម្រាមដៃមន្ត្រី និងបុគ្គលិកថ្មីចូលក្នុងប្រព័ន្ធ Finger Print និងការងារសំខាន់ៗមួយចំនួនទៀត។

### ៤.៥. ការងារសវនកម្មផ្ទៃក្នុង

ផ្នែកសវនកម្មផ្ទៃក្នុង មានភារកិច្ចចំពោះគ្រប់ការងារសវនកម្មផ្ទៃក្នុង លើការងារត្រួតពិនិត្យ តាមដានវាយតម្លៃ និងផ្តល់អនុសាសន៍លើការអនុវត្តន៍គោលនយោបាយសន្តិសុខសង្គម និងការអនុវត្តន៍បទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការអនុវត្តន៍ការងារតាមផ្នែកនីមួយៗ ដែលនៅក្នុងឆ្នាំ២០១៣ កន្លងមកនេះ ផ្នែកសវនកម្មផ្ទៃក្នុង សម្រេចលទ្ធផលបាន៖

- រៀបចំផែនការសវនកម្មតាមបណ្តាការិយាល័យសម្រាប់ឆ្នាំ២០១៣។
- ធ្វើសវនកម្មលើផ្នែករដ្ឋបាល ផ្នែកអធិការកិច្ច និងកិច្ចការនីតិកម្ម, ផ្នែកបញ្ជិកា និងភាគទាន និង ផ្នែកគោលនយោបាយ។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើជំនាញហិរញ្ញវត្ថុ។
- រៀបចំផែនការសកម្មភាពរយៈពេល៣ ឆ្នាំ និងរយៈពេល ៥ ឆ្នាំ។
- កសាងកម្មវិធីសវនកម្ម និងតេស្តត្រួតពិនិត្យផ្ទៃក្នុង។
- រៀបចំសំណួរ និងស្រាវជ្រាវឯកសារមួយចំនួន ដែលពាក់ព័ន្ធបទប្បញ្ញត្តិផ្សេងៗ ដើម្បីអនុវត្តលើនីតិវិធីសវនកម្មផ្ទៃក្នុង។

## ៥. ការងារគណៈកម្មការជំនាញ

### ៥.១. គណៈកម្មការ ស.ទ.ប.ក

គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ស.ទ.ប.ក) មានតួនាទីសិក្សាស្រាវជ្រាវរកមូលហេតុករណីសន្លប់របស់កម្មករនិយោជិត ចាត់វិធានការសង្គ្រោះបន្ទាន់ និងសម្របសម្រួលជាមួយមន្ទីរពេទ្យ ជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីឲ្យជនរងគ្រោះទទួលបានការសង្គ្រោះបន្ទាន់ និងរៀបចំការផ្សព្វផ្សាយ ពីកម្មវិធីបង្ការគ្រោះថ្នាក់ការងារ។ គណៈកម្មការ ស.ទ.ប.ក បាននឹងកំពុងរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំដូចភ្លៀងរលឹម ដើម្បីឲ្យនិយោជក តំណាងសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទទួលបានការអប់រំស្តីពីលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ ការទប់ស្កាត់ករណីកម្មករនិយោជិតដួលសន្លប់ និងបង្ការគ្រោះថ្នាក់ចរាចរណ៍ដោយមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត ក្នុងន័យទប់ស្កាត់ និងបង្ការគ្រោះថ្នាក់ការងារ ពិសេសករណីកម្មករនិយោជិត ដួលសន្លប់ឲ្យស្ថិតនៅកម្រិតសូន្យ។ ជាការគួរឲ្យកត់សំគាល់ សម្រាប់ឆ្នាំ២០១៣ កន្លងមកនេះ គណៈកម្មការបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំបានចំនួន ៣២ លើក មានរោងចក្រចំនួន ៧១ និងកម្មករនិយោជិតប្រមាណជា ០១ ម៉ឺននាក់។

*រូបភាពទី៥. ពិធីប្រជុំផ្សព្វផ្សាយអំពីលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម វិធានការទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ចរាចរណ៍ដោយមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត នៅរោងចក្រកាត់ដេរ SL Garment Processing (Cambodia) Co.,Ltd ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៣ ក្រោមអធិបតីភាព **ឯកឧត្តម ហ៊ុន ម៉ាណែត** នាយរងសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការបញ្ជាការដ្ឋានជាតិកំលាំងពិសេសប្រឆាំងភេរវកម្ម។*




ក្នុងបាតុភាពករណីដួលសន្លប់របស់កម្មករនិយោជិត គណៈកម្មការ ស.ទ.ប.ក បានចុះជួយសម្របសម្រួល ចាត់វិធានការកែលំអ និងជួយសង្គ្រោះបន្ទាន់ នៅរោងចក្រចំនួន ១៥ និងមានកម្មករនិយោជិតចំនួន ៨២៣ នាក់ ដោយក្នុងនោះរួមមាន៖

- រាជធានីភ្នំពេញមាន ០៣ រោងចក្រ មានកម្មករសន្លប់ចំនួន ១៥៤ នាក់
- ខេត្តកណ្តាលមាន ០៥ រោងចក្រ មានកម្មករសន្លប់ចំនួន ៤៣២ នាក់
- ខេត្តកំពង់ស្ពឺមាន ០៣ រោងចក្រ មានកម្មករសន្លប់ចំនួន ៦៨ នាក់
- ខេត្តកោះកុងមាន ០១ រោងចក្រ មានកម្មករសន្លប់ចំនួន ១៩ នាក់
- ខេត្តស្វាយរៀងមាន ០២ រោងចក្រ មានកម្មករសន្លប់ចំនួន ១២៥ នាក់
- ខេត្តកំពង់ចាមមាន ០១ រោងចក្រ មានកម្មករសន្លប់ចំនួន ២៥ នាក់។

## *ស្ថានភាពបាតុភាពករណីដួលសន្លប់កម្មករនិយោជិតនៅឆ្នាំ២០១២ និង ឆ្នាំ២០១៣*

*ក្រាហ្វិកទី៨ . ប្រៀបធៀបបាតុភាពករណីដួលសន្លប់កម្មករនិយោជិតឆ្នាំ២០១២ និងឆ្នាំ២០១៣*



បាតុភាពករណីដួលសន្លប់កម្មករនិយោជិត នៅឆ្នាំ២០១៣ នេះមានចំនួន ១៥ រោងចក្រ មានកម្មករនិយោជិតចំនួន ៨២៣ នាក់ បើប្រៀបធៀបទៅនឹងឆ្នាំ២០១២ ករណីនេះមានចំនួន ២៤ រោងចក្រ មានកម្មករនិយោជិតចំនួន ១.៦៨៦ នាក់។ ដូច្នេះបាតុភាពករណីដួលសន្លប់កម្មករនិយោជិតនៅឆ្នាំ២០១៣ នេះមានការថយចំនួន ០៩ រោងចក្រ ត្រូវជា ៣៨ ភាគរយ និងកម្មករនិយោជិតថយចុះចំនួន ៨៦៣ នាក់ ត្រូវជា ៥១ ភាគរយ។ ការថយចុះនូវករណីដួលសន្លប់នេះ គឺដោយសារគណៈកម្មការ ស.ទ.ប.ក បានចុះអង្កេតផ្ទាល់ចំពោះរោងចក្រដែលមានកម្មករដួលសន្លប់ ហើយបានរកឃើញចំណុចប្រឈមនានា និងបានចាត់វិធានការភ្លាមៗដើម្បីឲ្យនិយោជកធ្វើការកែលម្អ។ មួយវិញទៀត គណៈកម្មការបានធ្វើការផ្សព្វផ្សាយអប់រំផ្ទាល់នឹងកន្លែងការងារតាមបណ្តារោងចក្របានទូលំទូលាយ ហើយនិយោជក និងកម្មករនិយោជិតមានការយល់ដឹងកាន់តែច្បាស់ពីវិធីបង្ការផ្សេងៗនៅពេលមានឧប្បត្តិហេតុកើតឡើង។

## ៥.២. គណៈកម្មការវេជ្ជសាស្ត្រ នៃបេឡាជាតិរបបសន្តិសុខសង្គម

ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ គណៈកម្មការវេជ្ជសាស្ត្របានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព យុត្តិធម៌ មនសិការវិជ្ជាជីវៈ និងកសាងបានជំនឿទុកចិត្តពីសំណាក់មជ្ឈដ្ឋានទូទៅ និងសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម ជាពិសេសពីនិយោជកជាម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត មកលើការអនុវត្តរបស់បេឡាជាតិរបបសន្តិសុខសង្គម តាមរយៈការចូលរួមបង់ភាគទានធានារ៉ាប់រងហានិភ័យការងារ ជូនកម្មករនិយោជិត ហើយវាក៏បានជំរុញឲ្យពួកគេផ្តល់ព័ត៌មានពិតពីចំនួនកម្មករនិយោជិត និងពីប្រាក់ខែរបស់ពួកគេ ដើម្បីជៀសវាងការបាត់បង់អត្ថប្រយោជន៍ដែលមានចែងនៅក្នុងច្បាប់។

សម្រាប់ឆ្នាំ២០១៣ នេះ គណៈកម្មការវេជ្ជសាស្ត្រ បានរៀបចំកិច្ចប្រជុំវិនិច្ឆ័យកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ជូនជនរងគ្រោះចំនួន ១២២ នាក់ ដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម ក្នុងនោះរួមមាន៖

- ជនរងគ្រោះទើបទទួលគ្រោះថ្នាក់ចំនួន ១០០ នាក់ ក្នុងចំណោមនោះ គណៈកម្មការវេជ្ជសាស្ត្រសម្រេចផ្តល់កម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង ២០ ភាគរយចំនួន ៤៨ នាក់ និងចាប់ពី ២០ ភាគរយឡើងទៅមានចំនួន ៥០ នាក់ និង ០២ នាក់ទៀតអនុញ្ញាតឲ្យទទួលសេវាព្យាបាលបន្ត។
- ជនរងគ្រោះដែលត្រូវវិនិច្ឆ័យកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ឡើងវិញចំនួន ១៧ នាក់ ក្នុងចំណោម ១៧ នាក់ ខាងលើ គណៈកម្មការវេជ្ជសាស្ត្រសម្រេចផ្តល់កម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង ២០ ភាគរយចំនួន ១៣ នាក់ និងចាប់ពី ២០ ភាគរយឡើងមានចំនួន ០៤ នាក់។
- វិនិច្ឆ័យកម្មករនិយោជិតរងគ្រោះថ្នាក់ចំនួន ០៥ នាក់ ក្នុងនោះគណៈកម្មការបានសម្រេចជាគ្រោះថ្នាក់ការងារចំនួន ០២ នាក់ និង ០៣ នាក់ ទៀតមិនមែនជាគ្រោះថ្នាក់ការងារ។

## ៥.៣. គណៈកម្មការរៀបចំយន្តការនៃការទូទាត់សេវាសុខាភិបាល

គណៈកម្មការរៀបចំយន្តការនៃការទូទាត់សេវាសុខាភិបាល ស្ថិតនៅក្រោមគម្រោងបេឡាជាតិរបបសន្តិសុខសង្គម មានអក្សរកាត់ PPM (Provider Payment Mechanism Committee) ត្រូវបានបង្កើតឡើងនៅចុងខែកញ្ញា ឆ្នាំ២០១៣ ដោយប្រកាសអន្តរក្រសួង រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល។ គណៈកម្មការរៀបចំយន្តការនៃការទូទាត់សេវាសុខាភិបាល មានតួនាទីសិក្សាស្រាវជ្រាវ និងកំណត់ជ្រើសរើសយកយន្តការទូទាត់ថ្លៃសេវាសុខាភិបាល និងតម្លៃសេវាមូលដ្ឋានសុខាភិបាល កំណត់ប្រភេទ ក្រុមជំងឺ និងស្នើតម្លៃសេវាដែលត្រូវទូទាត់ទៅតាមក្រុមជំងឺនីមួយៗ និងកំណត់ពីយន្តការនៃការទូទាត់សេវាដល់មូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស។ គណៈកម្មការនេះ ក៏សិក្សាផងដែរពីយន្តការត្រួតពិនិត្យគុណភាពសេវា និងបែបបទទទួលបានសេវាដល់សមាជិក ប.ស.ស កំណត់បែបបទ និងនីតិវិធីដើម្បីឲ្យសមាជិក ប.ស.ស ទទួលបានសេវាសុខាភិបាល និងទាមទារការទូទាត់សេវាសុខាភិបាល សហការ និងសម្របសម្រួលជាមួយអង្គភាព ឬស្ថាប័នរដ្ឋ និងអង្គការជាតិ អន្តរជាតិពាក់ព័ន្ធនានា។ ជាការគួរឲ្យកត់សំគាល់សម្រាប់ឆ្នាំ២០១៣ កន្លងមកនេះ គណៈកម្មការសម្រេចការងារបាន៖

- ប្រជុំរៀបចំវិធីសាស្ត្រទូទាត់ថ្លៃសេវាសុខាភិបាលចំនួន ១៦ លើក។
- រៀបចំសិក្ខាសាលាស្តីពីវិធីសាស្ត្រទូទាត់ថ្លៃសេវាសុខាភិបាល ជាមួយអ្នកជំនាញសុខាភិបាល ចំនួន ០១ លើក។
- ពិនិត្យកែសម្រួលលើពង្រាងប្រកាសរួម ស្តីពីវិធីសាស្ត្រទូទាត់ថ្លៃសេវាធានារ៉ាប់រងសុខភាព។

## ៥.៤. ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត

បច្ចុប្បន្នគ្រោះថ្នាក់ចរាចរណ៍នៅតែជាបញ្ហាប្រឈមដ៏ធំរបស់សង្គមជាតិ ដោយសារតែចំនួនអ្នកស្លាប់ និងអ្នករបួសចេះតែបន្តកើតមានជារៀងរាល់ថ្ងៃទៅលើប្រជាជនកម្ពុជា ជាពិសេសទៅលើកម្មករនិយោជិត ដោយសារការធ្វើដំណើរទៅមកឥតឈប់ឈរជារៀងរាល់ថ្ងៃ។ ករណីនេះ បានរួមចំណែកជ្រៀតចូលដល់សណ្តាប់ធ្នាប់សាធារណៈក្នុងការបង្កើនបន្ទុកដល់ផ្នែកសន្តិសុខសង្គមមួយផ្នែកផងដែរ។ ដូច្នេះ ដោយមើលឃើញពីទុកលំបាកនានា និងដើម្បីបង្ការទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ទាំងនេះ បេឡាជាតិរបបសន្តិសុខសង្គមបានយកចិត្តទុកដាក់ និងបានបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត ដែលមានអក្សរកាត់ថា (ស.ផ.ក) ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ដែលមានតំណាងភាគីពាក់ព័ន្ធចូលរួម។ ស.ផ.ក មានតួនាទីក្នុងការកសាងផែនការសកម្មភាព សំដៅទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកដែលអាចកើតមានក្នុងពេលកម្មករនិយោជិតធ្វើដំណើរ ធ្វើការសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ វិភាគរកមូលហេតុចម្បងៗ ដែលនាំឲ្យកើតមានគ្រោះថ្នាក់ចរាចរណ៍ក្នុងពេលធ្វើដំណើររបស់កម្មករនិយោជិត និងស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងអ្នកបើកបរតាមបណ្តារោង

ចក្រ សហគ្រាស នៅទូទាំងប្រទេស។ ជាការគួរឲ្យកត់សំគាល់សម្រាប់ ឆ្នាំ២០១៣ កន្លងមកនេះក្រុមការងារ ស.ផ.ក សម្រេចការងារបានៈ

- ប្រជុំក្រុមការងារបានចំនួន ១០ លើក ដើម្បីរៀបចំផែនការសកម្មភាពឆ្នាំ២០១៣ និងឆ្នាំ ២០១៤, កសាងគ្រឿងឧបទេសសម្រាប់ផ្សព្វផ្សាយអប់រំ ផលិតស្ព័ត និងវីដេអូអប់រំ, បោះពុម្ព អាវយឺត មួក សម្រាប់ចែកជូនកម្មករនិយោជិត និងបោះពុម្ព Sticker បិទយានយន្ត។

*រូបភាពទី៦. កិច្ចប្រជុំក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិតលើកទី៣ (ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣)*



- ចុះស្រង់ស្ថិតិចំនួនអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត និងប្រជុំផ្សព្វផ្សាយអប់រំណែនាំ ស្តីពីច្បាប់ និងសុវត្ថិភាពចរាចរណ៍ដល់អ្នកបើកបរបានចំនួន ២៤ លើក រោងចក្រចំនួន ១៧២ អ្នកបើកបរដឹកកម្មករមានចំនួន ១.៨៦៧ នាក់ និងកម្មករនិយោជិតចំនួន ២.៨៨០ នាក់ ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកោះកុង និងខេត្តព្រះសីហនុ។
- បោះពុម្ពសៀវភៅច្បាប់ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា និងសៀវភៅសង្ខេប អប់រំ ស្តីពីការត្រួតពិនិត្យ ថែទាំបច្ចេកទេសយានយន្ត ការសង្គ្រោះបឋម និងច្បាប់ចរាចរណ៍។

## ៦. បញ្ហាប្រឈម

ការដាក់ឲ្យដំណើរការ របបធានារ៉ាប់រងហានិភ័យការងារជំហានដំបូង មានការលំបាកមួយចំនួន ទាក់ទងទៅនឹងការចូលរួមអនុវត្តច្បាប់របស់និយោជក កម្មករនិយោជិត ការផ្តល់សេវាសុខាភិបាលរបស់ មន្ទីរពេទ្យ និងសមត្ថភាពរបស់ស្ថាប័ន។

### *និយោជក ឬម្ចាស់សហគ្រាសមួយចំនួនតូច*

- សហការមិនបានល្អក្នុងការផ្តល់ព័ត៌មានទាក់ទងនឹងចំនួនកម្មករនិយោជិត ប្រាក់ឈ្នួល និង សាខារបស់ក្រុមហ៊ុន។

- មានការប្តូរឈ្មោះសហគ្រាស ឬ ប្តូរម្ចាស់ជាញឹកញាប់។
- រាយការណ៍ពីចំនួនកម្មករនិយោជិត និងបង់ភាគទានតាមខែនីមួយៗមានភាពយឺតយ៉ាវ។
- ផ្តល់របាយការណ៍ហានិភ័យការងារមិនច្បាស់លាស់ និងយឺតយ៉ាវ ដែលនាំឲ្យមានការលំបាកក្នុងការអង្កេតរកមូលហេតុគ្រោះថ្នាក់ការងារ និងនាំឲ្យការផ្តល់តាវកាលិកជូនជនរងគ្រោះយឺត។
- រក្សាទុកឯកសារទាមទារតាវកាលិករយៈពេលយូរ ដោយទុកសរុបរួមបានច្រើនករណី ឬដាច់ខែទើបបញ្ជូនមកបេឡាជាតិរបបសន្តិសុខសង្គម និងពេលបានតាវកាលិកមានភាពយឺតយ៉ាវក្នុងការផ្តល់ឲ្យជនរងគ្រោះវិញ។

### *កម្មករនិយោជិតមួយចំនួនតូច*

- មិនមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន (ខ្ចីឯកសារអ្នកដទៃមកប្រើ) ដូចជាអត្តសញ្ញាណប័ណ្ណ ប័ណ្ណស្នាក់នៅ និងសៀវភៅគ្រួសារ ឬប្រើប្រាស់ឯកសារមិនប្រក្រតី ដែលនាំឲ្យមានការលំបាកក្នុងការចុះបញ្ជិកាកម្មករនិយោជិត និងផ្ទៀងផ្ទាត់ឯកសារនៅពេលផ្តល់តាវកាលិក។
- រៀបអាពាហ៍ពិពាហ៍ហើយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ដែលជាហេតុមិនអាចទទួលបានតាវកាលិកឧត្តរជីវី សម្រាប់អ្នករស់នៅក្នុងបន្ទុក។
- ទៅទទួលការព្យាបាលនៅមន្ទីរពេទ្យ ដែលមិនបានចុះកិច្ចសន្យាជាមួយបេឡាជាតិរបបសន្តិសុខសង្គម និងប្រើប្រាស់សេវាមិនចំគោលដៅ។
- ពិបាកក្នុងការទាមទារសំណងព្យាបាលវេជ្ជសាស្ត្រដែលមិនមែនជាគ្រោះថ្នាក់ការងារ។
- ទាមទារតាវកាលិកចំពោះគ្រោះថ្នាក់មិនមែនការងារ។

### *មន្ទីរពេទ្យ និងមន្ទីរព្យាបាលមួយចំនួនតូច*

- គុណភាពនៃការផ្តល់សេវាវេជ្ជសាស្ត្រនៅមានកម្រិត។
- ផ្តល់សេវាមិនគោរពទៅតាមគោលការណ៍របស់ក្រសួងសុខាភិបាល, តាមបច្ចេកទេសវេជ្ជសាស្ត្រ, មិនចំគោលដៅ, ពន្លើសតម្លៃសេវា ឬការបង្កើតសេវាបន្ថែម និងពិបាកក្នុងការទាមទារឯកសារវេជ្ជសាស្ត្រ។
- ប្រើរថយន្តសង្គ្រោះបន្ទាន់ដឹកជនរងគ្រោះ ទាមទារតម្លៃសេវាខ្ពស់។
- មន្ទីរពេទ្យមួយចំនួនទុកអ្នករបួសឲ្យរង់ចាំយូរ, មានភាពជំអក់, មិនសូវយកចិត្តទុកដាក់, ប្រើពាក្យសម្តី ឬអាកប្បកិរិយាមិនសមរម្យរបស់គ្រូពេទ្យមកលើជនរងគ្រោះ ។

ក្រៅពីកត្តាខាងក្រៅ ក៏នៅមានកត្តាខាងក្នុងរបស់បេឡាជាតិរបបសន្តិសុខសង្គមផ្ទាល់ផងដែរ ទាក់ទងទៅនឹងសមត្ថភាពរបស់ស្ថាប័ន រួមមានទីកន្លែងធ្វើការនៅមានភាពតូចចង្អៀត, សមត្ថភាពមន្ត្រីមួយចំនួននៅមានកម្រិត, ប្រព័ន្ធគ្រប់គ្រងទិន្នន័យមិនទាន់មានភាពរលូន និងការផ្តល់តាវកាលិកមួយចំនួនមានការយឺតយូរ។ បញ្ហាដែលបានរកឃើញទាំងអស់នេះ វាមានទំនាក់ទំនងគ្នាទៅវិញទៅមក និងមានផលប៉ះពាល់ដល់ការអនុវត្តគោលនយោបាយធានារ៉ាប់រងហានិភ័យការងារ ពោលគឺការផ្តល់តាវកាលិកដល់ជនរងគ្រោះ។

## ៧. វិធានការដោះស្រាយ

ភាពច្បាស់លាស់, ការពង្រឹងការអនុវត្តច្បាប់, ការផ្សព្វផ្សាយ, ការសម្របសម្រួល និងដោះស្រាយបានឆាប់រហ័សទាន់ពេលវេលា, ការបណ្តុះបណ្តាលធនធានមនុស្ស, ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា, ការរៀបចំបែបបទ និងនីតិវិធីឲ្យបានកាន់តែល្អប្រសើរ គឺជាវិធានការដោះស្រាយដ៏សក្តិសិទ្ធ ដើម្បីធានាដល់ការអនុវត្តសេវាសន្តិសុខសង្គម ឲ្យមានប្រសិទ្ធភាព និងប្រកបដោយគុណភាព។ ក្នុងគោលបំណងដោះស្រាយបញ្ហាប្រឈមទាំងនេះ បេឡាជាតិរបបសន្តិសុខសង្គម បាននឹងកំពុងអនុវត្តនូវសកម្មភាពជាអាទិភាពមួយចំនួនដូចខាងក្រោម៖

- ផ្សព្វផ្សាយ ពន្យល់ណែនាំដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតឲ្យយល់ពីការអនុវត្តគោលនយោបាយធានាសន្តិសុខសង្គម ជាពិសេសរបបធានារ៉ាប់រងហានិភ័យការងារ និងរបបធានារ៉ាប់រងសុខភាព។
- សម្របសម្រួលជាមួយមន្ទីរពេទ្យ និងមន្ទីរសម្រាកព្យាបាល ដែលបានចុះកិច្ចសន្យាជាមួយបេឡាជាតិរបបសន្តិសុខសង្គម ឲ្យផ្តល់សេវាវេជ្ជសាស្ត្រកាន់តែមានប្រសិទ្ធភាព។
- ចាត់វិធានការរដ្ឋបាលចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានការយឺតយូរក្នុងការបង់ភាគទាន និងរាយការណ៍ពីចំនួនសាខា ប្រាក់បៀវត្សរ៍ និងកម្មករនិយោជិត មិនគ្រប់តាមចំនួនជាក់ស្តែង។
- បណ្តុះបណ្តាលធនធានមនុស្ស អភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា និងគោលនយោបាយធានាសន្តិសុខសង្គម ឲ្យបានកាន់តែល្អប្រសើរបន្ថែមទៀត។

## ៨. ទិសដៅអនុវត្តបន្តសម្រាប់ ឆ្នាំ២០១៤

ដើម្បីធានាដល់ការអនុវត្តច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឲ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា បេឡាជាតិរបបសន្តិសុខសង្គមបានដាក់ចេញនូវទិសដៅសំខាន់ៗមួយចំនួន សម្រាប់អនុវត្តនៅឆ្នាំ២០១៤ នៅក្នុងការផ្តល់សេវាធានាសន្តិសុខសង្គម ដល់កម្មករនិយោជិតដែលទទួលរងនូវយថាភាពផ្សេងៗ ឲ្យទទួលបាននូវការព្យាបាល ការថែទាំសុខភាព ធានាបាននូវសន្តិសុខប្រាក់ចំណូល និងដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម ដូចខាងក្រោម៖

- ពង្រីក និងពង្រឹងការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ តាមរយៈការពង្រីកដែនអនុវត្ត ពង្រឹងការអនុវត្តច្បាប់ និងអភិវឌ្ឍគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ ឲ្យបានកាន់តែល្អប្រសើរបន្ថែមទៀត, ការចាត់វិធានការបង្ការគ្រោះថ្នាក់ការងារ និងផ្តល់សេវាបុននីតិសម្បទា ដល់កម្មករនិយោជិតដែលជាសមាជិកនៃ ប.ស.ស ទទួលរងហានិភ័យការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ឲ្យទទួលបាននូវការស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីធានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញ និងដោយស្មើភាពនៃជនរងគ្រោះក្នុងសកម្មភាពនានារបស់សង្គម។

- ដាក់ឲ្យដំណើរការរបបធានារ៉ាប់រងសុខភាព ដើម្បីឲ្យកម្មករនិយោជិតទទួលបាននូវការថែទាំ និងព្យាបាលសុខភាព ការពារប្រឆាំងនឹងការប្រថុយប្រថាននៃការចំណាយលើមហន្តរាយផ្នែកសុខភាព និងការប្រឆាំងនឹងការខាតបង់ប្រាក់ចំណូល នៅពេលមានជំងឺ មាតុភាព និងយថាភាពផ្សេងៗទៀត។
- រៀបចំបែបបទ និងនីតិវិធីដាក់ឲ្យដំណើរការរបបប្រាក់សោធន តាមរយៈការសិក្សាលទ្ធភាព រៀបចំនូវយន្តការរបបប្រាក់សោធន ដោយបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ, ការកសាងសមត្ថភាពមន្ត្រី និងបុគ្គលិក, ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា និងបទដ្ឋានគតិយុត្ត សម្រាប់ជាមូលដ្ឋានអនុវត្ត។ នៅពេលដែលរបបនេះដំណើរការ កម្មករនិយោជិតដែលធ្វើការក្នុងវិស័យឯកជននឹងត្រូវទទួលបានរបបប្រាក់សោធនដូចមន្ត្រីរាជការផងដែរ។

## សេចក្តីសន្និដ្ឋាន

បេឡាជាតិរបបសន្តិសុខសង្គម បានអនុវត្តដោយជោគជ័យនូវជំហានទី១ របបធានារ៉ាប់រងហានិភ័យការងារ ដែលរហូតមកដល់ដំណាច់ឆ្នាំ២០១៣ នេះ បានពង្រីកវិសាលភាពគ្របដណ្តប់ទៅដល់ ២៤ រាជធានី-ខេត្ត នៅទូទាំងប្រទេស, ចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន បានចំនួន *៦.១០៧* មានកម្មករនិយោជិតចំនួន *៨៤៧.១៧៥* នាក់, ចុះកិច្ចសន្យាប្រើប្រាស់សេវាសុខាភិបាលជាមួយមន្ទីរពេទ្យ និងមន្ទីរព្យាបាលឯកជនចំនួន ៦៥, ផ្តល់តាវកាលិកហានិភ័យការងារ សម្រាប់ឆ្នាំ២០១៣ បានចំនួន ៩.៨០៦ ឯកសារ និងបានចុះធ្វើអធិការកិច្ចតាមបណ្តាសហគ្រាស គ្រឹះស្ថាន ពង្រឹងការអនុវត្តច្បាប់បានជាច្រើនករណី។ ក្រៅពីការងារចុះបញ្ជិកា ការទទួលភាគទាន ការផ្តល់តាវកាលិក និងការធ្វើអធិការកិច្ច បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំវិធានការបង្ការគ្រោះថ្នាក់ការងារ រៀបចំពង្រឹង ពង្រីក និងអភិវឌ្ឍការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារបានជាច្រើនទៀត ដើម្បីធានាបាននូវការផ្តល់សេវាសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ មួយវិញទៀត ប.ស.ស ក៏បានរៀបចំលិខិតបទដ្ឋានគតិយុត្ត នីតិវិធី និងបែបបទការងារសម្រាប់អនុវត្តជំហានទី២ របបធានារ៉ាប់រងសុខភាព ដែលនឹងដាក់ឲ្យដំណើរការជាផ្លូវការនៅឆ្នាំ២០១៤ នេះ ដើម្បីឲ្យកម្មករនិយោជិតទទួលបាននូវការថែទាំ និងព្យាបាលសុខភាព ការពារប្រឆាំងនឹងការប្រថុយប្រថាននៃការចំណាយលើមហន្តរាយផ្នែកសុខភាព និងការប្រឆាំងនឹងការខាតបង់ប្រាក់ចំណូល នៅពេលមានជំងឺ មាតុភាព និងយថាភាពផ្សេងៗទៀត។

ការសម្រេចបាននូវលទ្ធផលការងារគួរជាទីមោទនៈខាងលើនេះ ដោយសារថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក បេឡាជាតិរបបសន្តិសុខសង្គមទាំងអស់ បានយកចិត្តទុកដាក់បំពេញការងារប្រកបដោយមនសិកាវិជ្ជាជីវៈ និងឆន្ទៈខ្ពស់ រួមទាំងមានការគាំទ្រសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា អង្គការជាតិ អន្តរជាតិ និងការចូលរួមអនុវត្តច្បាប់បានល្អពីសំណាក់ម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតផងដែរ។

ទន្ទឹមនឹងលទ្ធផលការងារខាងលើ បេឡាជាតិរបបសន្តិសុខសង្គម បានសង្កេតឃើញនៅមានបញ្ហាប្រឈមមួយចំនួនទៀត ទាក់ទងនឹងការអនុវត្តកាតព្វកិច្ចមិនទាន់បានល្អប្រសើរពីសំណាក់និយោជក និង

កម្មករនិយោជិតមួយចំនួនតូច គុណភាពនៃការផ្តល់សេវាវេជ្ជសាស្ត្រនៅមានកម្រិត និងមានការយឺតយូរក្នុងការផ្តល់តាវកាលិកជាយថាហេតុរបស់ខ្លួនផងដែរ។ មួយវិញទៀតទាក់ទងនឹងបញ្ហាប្រឈមនេះ បេឡាជាតិរបបសន្តិសុខសង្គម បានកត់សំគាល់ឃើញថា ចំនួនគ្រោះថ្នាក់ការងារ មានការកើនឡើងនៅគ្រប់ករណីជាពិសេសគ្រោះថ្នាក់នៅពេលធ្វើដំណើរ មានចំនួនច្រើនបន្ទាប់ពីគ្រោះថ្នាក់នៅកន្លែងធ្វើការ ដែលភាគច្រើនជាគ្រោះថ្នាក់ធ្ងន់ធ្ងរ និងបណ្តាលឲ្យបាត់បង់ជីវិតទៀតផង ហើយជាករណីមួយដែលមិនទាក់ទងទៅនឹងលក្ខខណ្ឌការងារនៅនឹងកន្លែងធ្វើការ ដែលវាទាក់ទងជាចម្បងជាមួយនឹងការយល់ដឹង ឬ ការប្រុងប្រយ័ត្នរបស់កម្មករនិយោជិតខ្លួនឯងផ្ទាល់ ក្នុងការប្រើប្រាស់មធ្យោបាយធ្វើដំណើរទៅមក ដើម្បីបំពេញការងារ។

ដូចនេះ វាទាមទារឲ្យមានការបន្តជួយជ្រោមជ្រែង គាំទ្រសហការបន្ថែមទៀត ពីសំណាក់ក្រសួងស្ថាប័នពាក់ព័ន្ធនានា អង្គការជាតិ អន្តរជាតិ នៅក្នុងការអភិវឌ្ឍន៍វិស័យសន្តិសុខសង្គមនៅកម្ពុជាឲ្យមានការរីកចម្រើន និងសូមឲ្យមានការចូលរួមយ៉ាងសកម្ម ក្នុងការចាត់វិធានការអប់រំ ផ្សព្វផ្សាយ ដើម្បីបង្ការ និងទប់ស្កាត់ ក្នុងការកម្រិតគ្រោះថ្នាក់ការងារ ឲ្យនៅទាបបំផុត ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ស្សិរភាពសង្គម។ ម្យ៉ាងវិញទៀតកម្មករនិយោជិតខ្លួនឯងផ្ទាល់ ត្រូវមានការយល់ដឹងចំពោះបញ្ហាសុខភាព និងប្រុងប្រយ័ត្នខ្ពស់នៅក្នុងការបំពេញការងារ ជាពិសេសការធ្វើដំណើរទៅមក ដើម្បីជៀសវាងកុំឲ្យមានគ្រោះថ្នាក់ ព្រោះវានាំឲ្យខាតបង់ការងារ ពេលវេលា ថវិកា និងជាយថាហេតុបណ្តាលឲ្យបាត់បង់ដល់អាយុជីវិតទៀតផង។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤

**នាយក**

# អាស័យដ្ឋាន និងលេខទូរស័ព្ទការិយាល័យសាខា ប.ស.ស តាមបណ្តាខេត្ត

| ល.រ | ខេត្ត | អាស័យដ្ឋាន | ទំនាក់ទំនង |
|---|---|---|---|
| ១ | ខេត្តកណ្តាល | ផ្ទះលេខ១ ភូមិដើមមៀន សង្កាត់ដើម មៀនក្រុងតាខ្មៅ ខេត្តកណ្តាល | H/P: ០១២ ៩០៣ ៧៣៥<br>០១២ ៨៥៤ ២២៦ |
| ២ | ខេត្តកំពង់ស្ពឺ | ផ្ទះលេខ៣៦A ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល | H/P: ០១២ ២៨៦ ៨៧៩<br>០៩២ ៧៩៥ ២៤៥ |
| ៣ | ខេត្តស្វាយរៀង | ភូមិបាវិតលើ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង | Tell: ០៤៤ ៩៤៦ ២៦៦<br>H/P: ០៧៧ ៦៦៣ ២១៤<br>០១១ ៣២៨ ៤១៥<br>Email: nssf_bmc@nssf.gov.kh |
| ៤ | ខេត្តព្រះសីហនុ | ភូមិ២ ឃុំ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ | Tell: ០៣៤ ៩៣៤ ៦០៦<br>H/P: ០៧៧ ៦៦៣ ២១៥<br>០១៦ ៥៦៥ ៩៥៨<br>Email: nssf_shv@nssf.gov.kh |
| ៥ | ខេត្តកំពង់ឆ្នាំង | ភូមិបារាំង សង្កាត់ផ្សេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង | Tell: ០២៦ ៩៨៨ ៨៩១<br>H/P: ០៧៧ ៦៦៣ ២១៦<br>០១៦ ៨៨៤ ៣៤៨<br>Email: nssf_kcn@nssf.gov.kh |
| ៦ | ខេត្តសៀមរាប | ផ្ទះលេខ០៦៨ ភូមិដំដែកថ្មី ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប | Tell: ០៦៣ ៣៩៥ ៩៣៤<br>H/P: ០៧៧ ៦៦៣ ២១៧<br>០១២ ៩៨៤ ១៧៥<br>Email: nssf_srp@nssf.gov.kh |
| ៧ | ខេត្តបន្ទាយមានជ័យ | ផ្ទះលេខ២៥ ភូមិបាលិលេយ្យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ | Tell: ០៥៤ ៩៦៧ ៤៤៩<br>H/P: ០៧៧ ៦៦៣ ២១៨<br>០៩២ ៨៩៨ ៣៨៨<br>Email: nssf_bmc@nssf.gov.kh |
| ៨ | ខេត្តកំពង់ចាម | ផ្លូវជាតិលេខ៧ ភូមិ៤ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម | Tell: ០៤២ ៦៥២ ១៩៩ ៩<br>H/P: ០១២ ៥២០ ៧៦៧<br>០១១ ៩៦៣ ០៤៩ |
| ៩ | ខេត្តក្រចេះ | ភូមិអូរឫស្សី១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ | H/P: ០៩២ ៨៧៣ ០៥១<br>០៧៧ ៥៧០ ៩០៤ |

| | | | |
|---|---|---|---|
| ១០ | ខេត្តព្រៃវែង | ភូមិ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង | H/P: ០៩២ ៧០៨ ៨០៣ |
| ១១ | ខេត្តតាកែវ | ភូមិ២ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ | H/P: ០៩៧ ២០០ ២៨៥ ២ |
| ១២ | ខេត្តកែប | ឃុំកែប សង្កាត់កែប ក្រុងកែប ខេត្តកែប | H/P: ០៩៧ ៧៦៧ ៦០០ ៥ |
| ១៣ | ខេត្តកំពត | ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត | H/P: ០១២ ៦២៣ ៣៣២<br>០១៧ ៩២៦ ៨៥០ |
| ១៤ | ខេត្តកោះកុង | ភូមិ៤ សង្កាត់ដងទង់ ក្រុងខេមរៈភូមិន្ទ ខេត្តកោះកុង | H/P: ០៩៧ ៩៧៣ ៩០០ ៦ |
| ១៥ | ខេត្តបាត់ដំបង | ភូមិព្រែកព្រះស្តេច សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង | H/P: ០៨៩ ៨៥៣ ៧១៧<br>០៩៧ ៧៤៧ ២៧៧ ២ |
| ១៦ | ខេត្តប៉ៃលិន | ភូមិវត្ត សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន | H/P: ០៨៦ ៨៩៣ ៧៧៧ |
| ១៧ | ខេត្តពោធិសាត់ | ភូមិផ្ទះព្រៃ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ | H/P: ០៩២ ៧០៧ ៣៨៥<br>០១៧ ៣៩២ ៥៥២ |
| ១៨ | ខេត្តកំពង់ធំ | ផ្ទះលេខ២៧ ផ្លូវប្រជាធិបតេយ្យ ភូមិ៧ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន | H/P: ០៩២ ៧៦៤ ៨៩៧<br>០៩២ ៧៤៧ ០៩៩ |
| ១៩ | ខេត្តស្ទឹងត្រែង | ភូមិថ្មលាត សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង | H/P: ០១២ ៤០៥ ៤៥១ |
| ២០ | ខេត្តរតនគិរី | ភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី | H/P: ០១១ ៤៥១ ៧៧៧<br>០៨៨ ៨៨ ២២ ៦៦១ |
| ២១ | ខេត្តមណ្ឌលគិរី | ភូមិចំបក់ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី | H/P: ០១២ ២០៥ ៧៥៦ |
| ២២ | ខេត្តឧត្តរមានជ័យ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ខេត្តរតនគិរី | H/P: ០៩៧ ៥២៣ ៤៦៦ ៦ |
| ២៣ | ខេត្តព្រះវិហារ | ភូមិកណ្តាល សង្កាត់កំពង់ប្រណាក់ ក្រុងព្រះវិហារ ខេត្តព្រះវិហារ | H/P: ០៩៧ ៣៦ ៦៦ ០៦០ |

# មន្ទីរពេទ្យ និងមណ្ឌលសុខភាពដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស |
|---|---|---|---|---|
| ០១ | មន្ទីរពេទ្យកាល់ម៉ែត | ១១៩ | ០២៣ ៤២៦ ៩៤៨<br>០២៣ ៧២៤ ៨៩១ | ០៩៧ ៦៨៧ ២៤២ ៦ |
| ០២ | មន្ទីរពេទ្យព្រះកុសុមៈ | ១១៩ | ០១២ ៦៥៧ ៦៥៣<br>០១៦ ៩០៩ ៧៧៤ | ០៩៧ ៦៨៧ ២៤២ ៩ |
| ០៣ | មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ១១៩ | ០២៣ ២១៧ ៧៦៤ | ០៩៧ ៦៨៧ ២៤២ ៧ |
| ០៤ | មន្ទីរពេទ្យព្រះអង្គឌួង | | ០១១ ៧៥៥ ១១៩<br>០៧៧ ៥៥០ ០១៧ | |
| ០៥ | មន្ទីរពេទ្យជ័យជំនះ | ០១៥ ៥១៩ ១១៩ | ០១២ ៩១២ ៥២៣ | ០៩៧ ៦៨៧ ២៤២ ៨ |
| ០៦ | មន្ទីរពេទ្យបង្អែកកំពង់ស្ពឺ | ០១៦ ៦៩៦ ៤៨០ | ០២៥ ៩៨៧ ៣១៣ | ០៩៧ ៧៨៣ ៩៣៩ ១<br>០១០ ៨៥៧ ៩២៣ |
| ០៧ | មណ្ឌលសុខភាពបែកចាន | ០១២ ១៧៥ ៨២៨ ៥<br>០៩៧ ៤៩៩ ៨៩៣ ៦ | ០១២ ៨៩៤ ២៦០ | ០៩៧ ២៩៩ ៦៦៦ ៩ |
| ០៨ | មន្ទីរពេទ្យបង្អែកអង្គស្នួល | ០១២ ៥៨១ ៦៣៩ | ០១២ ៨៩៤ ២៦០ | |
| ០៩ | មន្ទីរពេទ្យបង្អែកស្វាយរៀង | ០៤៤ ៩៤៥ ១១១ | ០១២ ៩៥៣ ៩៧៥ | ០៩៧ ៧៨៣ ៨៧៦ ៥ |
| ១០ | មន្ទីរពេទ្យបង្អែកជីភូ | ០១១ ៣៩៤ ១៧៨ | ០១២ ៨០៥ ២៣៦ | |
| ១១ | មន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង | ០២៦ ៩៨៨ ១១១ | ០១៥ ២៥០ ១១១ | ០៨៩ ៨៥៥ ៣៨៥ |
| ១២ | មន្ទីរពេទ្យបង្អែកកំពង់ត្រឡាច | ០៨៥ ៥៨៧ ៧៥៧ | ០៨៥ ៥៨៧ ៧៩០ | ០៨៨ ៩៧២ ១០១ ៦ |
| ១៣ | មន្ទីរពេទ្យបង្អែកសៀមរាប | ០១៦ ៨០០ ១១៩ | ០១២ ៩២៥ ០៦១ | ០៨៨ ៩៧២ ១០១ ២<br>០៧៧ ៥៥៥ ០៥០ |
| ១៤ | មន្ទីរពេទ្យបង្អែកប៉ោយប៉ែត | ០១២ ៧៨៦ ២៨៦ | ០៨៩ ៨៣៧ ៦៣៧ | ០៨៨ ៩៧២ ១០១ ៣ |
| ១៥ | មន្ទីរពេទ្យបង្អែកខេត្តមិត្តភាព កម្ពុជា-ជប៉ុន | ០១២ ៩៣២ ៥២១ | ០១២ ៩២៣ ៣៥៤ | |
| ១៦ | មន្ទីរពេទ្យបង្អែកសិរីសោភ័ណ | ០១២ ៩១០ ៤៦៧ | ០១២ ៨៥៤ ៩៨៣ | |
| ១៧ | មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ | ០១៦ ៦៨៦ ៨៤៣ | ០១២ ៧១២ ៦៤៦ | ០៨៨ ៩៧២ ១០១ ៤ |
| ១៨ | មន្ទីរពេទ្យ CT (ខេត្តព្រះសីហនុ) | ០៨៩ ៨៨ ៦៦៦៦<br>០៨៥ ៨៨ ៦៦៦៦ | ០៨១ ៨៨ ៦៦ ៦៦ | |
| ១៩ | មន្ទីរពេទ្យបង្អែកស្រុកជើងព្រៃ | ០១២ ៦៦៧ ៤៨៦<br>០៨៨ ៧៧៤ ៤៧៨ ៨ | ០១៧ ៤២៣ ៥៤៨ | ០៩៣ ៨៧១ ០៤៣ |
| ២០ | មន្ទីរពេទ្យបង្អែកស្រុកពញាក្រែក | ០៨៨ ៧៧៤ ៤៧១ ១<br>០១១ ៦៦៩ ៤០៨<br>០៨៥ ៤១៤ ៨១៩ | ០៨៥ ៤១៤ ៨១៩ | ០១២ ៥២០ ៧៦៧ |

| | | | | |
|---|---|---|---|---|
| ២១ | មន្ទីរពេទ្យបង្អែកស្រុកត្បូងឃ្មុំ | ០៨៨ ៧៧៤ ៤៧០ ០ | ០១២ ៩៥៥ ៦៥០<br>០១១ ៨៦២ ០៣៩ | ០៨៨ ៨៨៦ ១២១ ៨ |
| ២២ | មន្ទីរពេទ្យបង្អែកខេត្តក្រចេះ | ០៧២ ២១០ ៣៩១ ០<br>១២ ៨២២ ៣៩១ | ០១២ ៩៣១ ៨៦៨ | ០៩៧ ៧៩៧ ៨៩៩ ៩<br>០៩៧ ៩៨៩ ៦៦៩ ១ |
| ២៣ | មន្ទីរពេទ្យបង្អែកស្រុកឆ្លូង | ០៩២ ៨៦៦ ៤១៣<br>០១៧ ៩០៩ ៦៥៣ | ០១២ ៣៦៧ ៧០២ | |
| ២៤ | មន្ទីរពេទ្យបង្អែកស្រុកស្នួល | ០៩៧ ៧៥២ ៧៩៩ ៦<br>០១២ ៥២៧ ៩៩៦ | ០៩៧ ៦៥៩ ៧ ២៩ ៩ | ០៨៨ ៦៧៧ ២៨៣ ២ |
| ២៥ | មន្ទីរពេទ្យបង្អែកអ្នកលឿង | ០១២ ៧៩៥ ៣១៩ | ០១២ ៦៦០ ៨១៥ | |
| ២៦ | មន្ទីរពេទ្យបង្អែកព្រៃវែង | ០៩៧ ២៣៤ ១៧៨ ២<br>០១២ ៦៥៨ ៣០៣ | ០១២ ៦៥៨ ៣០៣ | ០៩២ ៧០៨ ៨០៣ |
| ២៧ | មន្ទីរពេទ្យបង្អែកកោះធំ | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨ | |
| ២៨ | មន្ទីរពេទ្យបង្អែកស្រុកស្អាង | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨ | ០៧៧ ៥៧០ ៩០៨ |
| ២៩ | មន្ទីរពេទ្យខេត្តតាកែវ | ០១២ ៩៣៥ ៨១៤<br>០១២ ១៧២ ៨៣៤ ៨ | | ០១០ ៩០៩ ០៩៧ |
| ៣០ | មន្ទីរពេទ្យបង្អែកបាទី | ០១២ ៧២៤ ០៩៣<br>០៩៧ ៦៤៧ ៤៣០ ៣ | ០៣២ ៦៩០ ១៩៣ ៩ | ០១៧ ៣៨៧ ២៥២ |
| ៣១ | មណ្ឌលសុខភាពទួលគោក | ១១៩ | ០១២ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | |
| ៣២ | មន្ទីរពេទ្យបង្អែកសម្តេចឪ | ១១៩ | ០១២ ៩៣២ ៨០៣<br>០១២ ៨៦៤ ៥០៩ | |
| ៣៣ | មណ្ឌលសុខភាពទឹកថ្លា | ១១៩ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | |
| ៣៤ | មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង | ១១៩ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | ០៧៨ ៦១៥ ៩៨៩<br>០១២ ៨៨៤ ៧៦៦ |
| ៣៥ | មន្ទីរពេទ្យបង្អែកខេត្តកែប | | ០១២ ៨២៥ ២៧៧<br>០១២ ៩១២ ៣២០<br>០១២ ៤៥៦ ២៤៧ | ០៩៧ ៧៦៥ ៦០០ ៥ |
| ៣៦ | មន្ទីរពេទ្យបង្អែកខេត្តកំពត | ០១២ ២៩៧ ៦២៨ | | |
| ៣៧ | មន្ទីរពេទ្យបង្អែកកំពង់ត្រាច | ០១២ ៧៣៣ ៤៦៨<br>០៩២ ៣៨៣ ៦៣២ | | |
| ៣៨ | មន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់ | ១៣៥៣ | ០១២ ៨២៨ ៤៦៦ | |
| ៣៩ | មន្ទីរពេទ្យបង្អែកស្រែអំបិល | ០១៦ ២២២ ១៨៦<br>០១៦ ៨៧៧ ០០៦ | | ០១២ ៧៣៣ ៦២៧ |

| | | | | |
|---|---|---|---|---|
| ៤០ | មន្ទីរពេទ្យបង្អែកខេត្តកោះកុង | ០១៦ ៣០០ ១១៩ | | |
| ៤១ | មន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន | ០៩៧ ៦២៨ ៤៣៣៣ | | ០១២៩៩៤២៧២<br>០៩៧ ៧៩ ៩៩ ៣០០ |
| ៤២ | មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង | ០១២ ២៦៩ ៣៨៨ | | ០៩៥ ៨៨៥ ៨៥៥ |
| ៤៣ | មណ្ឌលសុខភាពព្រែកអញ្ចាញ | | ០១២ ៦៦៥ ០៣៩ | ០៩៧ ៨៩៩ ៨៧២ ៤ |
| ៤៤ | មន្ទីរពេទ្យបង្អែកប៊ុន រ៉ានី ហ៊ុន សែន រកាកោង | ០៩២ ៤០៧ ៨១៨ | | |
| ៤៥ | មណ្ឌលសុខភាពត្រាំខ្នារ | ០៨១ ៤៤៤ ១៧៤ | | |
| ៤៦ | មន្ទីរពេទ្យបង្អែកឧត្តុង្គ | ០៧៨ ៨៩១ ៩១៣ | | |
| ៤៧ | មន្ទីរពេទ្យបារាយណ៍-សន្ទុក | ០១២ ៩២៧ ១៤២ | | |
| ៤៨ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ | ០១៧ ៣៩៨ ៧៥០ | | |
| ៤៩ | មន្ទីរពេទ្យបង្អែកស្ទោង | ០១២ ៧៦៨ ៤៤៣ | | |
| ៥០ | មន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែង | ០៩២ ៧៩៩ ៤៦៤<br>០៨៨ ៨៨៤ ៩៤៨៣<br>០៩៧ ៩៧៨ ០៨៧៨ | | |
| ៥១ | មន្ទីរពេទ្យបង្អែកខេត្តរតនគិរី | ០១៧ ៩៣៦ ៩៤៥<br>០១២ ៨៤០ ៨០៨<br>០១៧ ៣៥៧ ៣២០<br>០១២ ៥០៥ ០០៨<br>០១២ ៥២៨ ០០៥ | | |
| ៥២ | មន្ទីរពេទ្យបង្អែកសែនមនោរម្យ | ០៩៧ ៧១២ ១៤៤ ៥<br>០១២ ៩៦១ ៧៤៤<br>០៩៧ ៤៧៣ ៩៦៨ ៥<br>០៨៨ ៩៩៨ ៦៥៦ ៦ | | |
| ៥៣ | មន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ | ០៩២ ១៤១ ៨៣៥ | ០៧៨ ២២៩ ៧៩៧<br>០៧៨ ៩៧៩ ៧២៩ | |
| ៥៤ | មន្ទីរពេទ្យបង្អែក ១៦ មករា | ០១២ ៣៧១ ៦១៨ | ០១២ ៤២៦៥១៩<br>០១២ ៨៩២ ៩០៩ | |
| ៥៥ | មន្ទីរពេទ្យបង្អែកស្រុកមេមត់ | ០៨៨ ៧៧ ៤៤ ៧២២<br>០១២ ៩៦១ ៣៩៣ | ០១២ ៨៧៣ ១២៧ | |
| ៥៦ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម | ០១២ ៨២៣ ៧០៩<br>០៩២ ៩៥៧ ៨៧១ | ០៩២ ៩៣៩ ៤៨០<br>០៩២ ៩១៧ ៣៨៨ | |
| ៥៧ | មន្ទីរពេទ្យបង្អែកព្រែកកក់(ស្ទឹងត្រង់) | ០១២ ៩០៤ ៣០៦<br>០៩២ ៣២២ ៤១៣ | ០១២ ៤៩៥ ១៤៨<br>០១១ ២៩៤ ៥៣២ | |
| ៥៨ | មណ្ឌលសុខភាពវិហារសួគ៌ | ០៧៧ ៩២៦ ៦៩២ | ០១២ ៨៣២ ៣៤៣<br>០១២ ៤៩៥ ៩៨៣ | |

| | | | | |
|---|---|---|---|---|
| ៥៩ | មន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង | ០៧៦ ៥២៦ ២៤៩១ | ០៧៧ ៥០៨ ០៥៧ | |
| ៦០ | មណ្ឌលសុខភាពអូរស្មាច់ | ០១១ ៧៣៦ ៨៨៦ | | |
| ៦១ | មណ្ឌលសុខភាពភ្នំដែក | ០៩២ ២២៧ ៦១៦ | ០៩៧ ៣៩៤ ៤៦៦ ៩ | |
| ៦២ | មន្ទីរពេទ្យបង្អែកពារាំង | ០៩២ ៦៥៣ ៥៩៥ | ០៩២ ២២៣ ៦១៤<br>០៨៣ ៦៩០ ០៩០ ៥ | |
| ៦៣ | មន្ទីរពេទ្យបង្អែកកំចាយមារ | ០១២ ៦៩៣ ៩៤០<br>០១២ ៥៨៨ ៤៩៥<br>០៩៥ ៨៨១ ៧០៧ | | |
| ៦៤ | មណ្ឌលសុខភាពក្មៀងរាយ | ០១២ ៦៥៨ ៣០៣<br>០១២ ៤៣៩ ៣៤៣<br>០១២ ២៩៧ ៤៩១ | | |
| ៦៥ | មណ្ឌលសុខភាពស្ទឹងមានជ័យ | | ០១២ ៩៧១ ៤៧៦<br>០១១ ២៦២ ៦៥៦ | ០៧៧ ៦៣៦ ៣៦០ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩០៣.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងសមាសភាព
# ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
